**អេ អិម អេ (ខេមបូឌា) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

# របាយការណ៍ក្រុមប្រឹក្សាភិបាល
# និង
# របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

លេខចុះបញ្ជីពាណិជ្ជកម្ម៖ ០០០០១១២១

**អេ អិម អេ (ខេមបូឌា) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុ**

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

**មាតិកា**


| | ទំព័រ |
|---|---|
| របាយការណ៍ក្រុមប្រឹក្សាភិបាល | ១-៥ |
| របាយការណ៍ហិរញ្ញវត្ថុ | |
| របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ | ៦ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៧-៨ |
| របាយការណ៍បម្រែបម្រួលមូលធន | ៩ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១០-១៥ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ១៦-៦៦ |
| របាយការណ៍សវនករឯករាជ្យ | ៦៧-៧១ |

## អេ អិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

### របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍របស់ខ្លួនដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

### សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការធ្វើសកម្មភាពលក់យានយន្ត គ្រឿងបន្លាស់ គ្រឿងចក្រធន់ធ្ងន់ និងការផ្តល់សេវាកម្មជួសជុល និងថែទាំ។

នៅក្នុងអំឡុងការិយបរិច្ឆេទនេះ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពអាជីវកម្មចម្បងទាំងនេះទេ។

### លទ្ធផលប្រតិបត្តិការ

| | ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២៣.៨០៦.២៧០ | ៩៧.០៥៨.១៦៣ |

### ភាគលាភ

ភាគលាភដែលបានប្រកាសដោយក្រុមហ៊ុនតាំងពីចុងការិយបរិច្ឆេទមុនមានដូចខាងក្រោម៖

| | ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|
| ភាគលាភបណ្តោះអាសន្ននៃ ៣.៤០០ ដុល្លារអាមេរិក (១៣.៧៥៣.០០០ រៀល) ក្នុងមួយភាគហ៊ុននៃ ៤.០០០ ដុល្លារអាមេរិក (១៦.០០០.០០០ រៀល) សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៣.៤០០.០០០ | ១៣.៧៥៣.០០០ |
| ភាគលាភបណ្តោះអាសន្ននៃ ៣.០០០ ដុល្លារអាមេរិក (១២.១៣៥.០០០ រៀល) ក្នុងមួយភាគហ៊ុននៃ ៤.០០០ ដុល្លារអាមេរិក (១៦.០០០.០០០ រៀល) សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៣.០០០.០០០ | ១២.១៣៥.០០០ |
| | ៦.៤០០.០០០ | ២៥.៨៨៨.០០០ |

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលបានអនុម័តភាគលាភបន្ថែមចំនួន ១.៩០០ ដុល្លារអាមេរិក (ប្រមាណ ៧.៦៨៥.៥០០ រៀល) ក្នុងមួយភាគហ៊ុននៃ ៤.០០០ ដុល្លារអាមេរិក (១៦.០០០.០០០ រៀល) សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលមានទឹកប្រាក់សរុបចំនួន ១.៩០០.០០០ ដុល្លារអាមេរិក (ប្រមាណ ៧.៦៨៥.៥០០.០០០ រៀល)។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុបច្ចុប្បន្ន មិនបានកត់ត្រាភាគលាភបន្ថែមនេះជាបំណុលទេ។ ភាគលាភបន្ថែមនេះនឹងត្រូវកត់ត្រាក្នុងគណនីមូលធន ជាការបែងចែកប្រាក់ចំណេញរក្សាទុក ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

## អេ អិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង ឬសំវិធានធនក្នុងអំឡុងការិយបរិច្ឆេទនេះទេ លុះត្រាតែបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

### បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថាវិធានការទាក់ទងនឹងការលុបចោលបំណុលពិបាកទារ និងការធ្វើសំវិធានធនលើបំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់បំណុលពិបាកទារដែលបានដឹងត្រូវបានលុបចោល និងបានធ្វើសំវិធានធនគ្រប់គ្រាន់លើបំណុលដែលជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនាំឱ្យចំនួនទឹកប្រាក់នៃបំណុលពិបាកទារដែលបានលុបចោល ឬទឹកប្រាក់នៃសំវិធានធនលើបំណុលជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនគ្រប់គ្រាន់ជាសារវន្តឡើយ។

### ទ្រព្យសកម្មចរន្ត

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីធានាថាទ្រព្យសកម្មចរន្តដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាដែលកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលបានរំពឹងទុកនឹងអាចលក់បានលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវឡើយ។

### វិធីសាស្ត្រក្នុងការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម ឬបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលជាយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) ការទាមទារទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទ ដើម្បីធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

(២) បំណុលជាយថាហេតុណាមួយ ដែលកើតមានឡើងចំពោះក្រុមហ៊ុនចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទឡើយ។

# អេ អិម អេ ( ខេមបូឌា ) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ( ត )

### បំណុលជាយថាហេតុ និងបំណុលផ្សេងៗ (ត)

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលជាយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវទាមទារឲ្យសង ឬអាចនឹងត្រូវទាមទារឲ្យសងក្នុងរយៈពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទដែលនឹង ឬអាចធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការសងបំណុលនៅថ្ងៃកំណត់សងនោះទេ។

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានបញ្ចូលនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលបណ្តាលឱ្យតួលេខនៃចំនួនណាមួយដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនជាមានភាពមិនត្រឹមត្រូវនោះទេ។

### ប្រតិបត្តិការជាសារវន្ត និងមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល៖

(i) លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដោយកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ និង

(ii) ពុំមានកត្តា ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេក្នុងចន្លោះពេលរវាងចុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលអាចនាំឱ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរៀបចំរបាយការណ៍នេះទេ។

### ការបោះផ្សាយភាគហ៊ុន និងបំណុល

លើកលែងតែបានបង្ហាញក្នុងកំណត់សម្គាល់ ៣០ នៃរបាយការណ៍ហិរញ្ញវត្ថុ ក្រុមហ៊ុនមិនមានបោះផ្សាយភាគហ៊ុនថ្មី ឬបំណុលនោះទេ នៅក្នុងអំឡុងការិយបរិច្ឆេទនេះ។

### ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន

ក្រុមប្រឹក្សាភិបាលដែលបម្រើការងារក្នុងអំឡុងការិយបរិច្ឆេទ និងអំឡុងពេលចាប់ពីចុងការិយបរិច្ឆេទដល់កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ រួមមាន៖

Kevin Robert Whitcraft

Thomas Arthur Whitcraft

Ngorn Saing

Christopher Gowen Manley

Ith Vichit

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ក្រុមហ៊ុនមេ

ក្រុមប្រឹក្សាភិបាល ចាត់ទុកក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនដែលបានបង្កើតឡើងក្នុងទីក្រុងហុងកុង និងក្រុមហ៊ុន Whitbro LLC ដែលជាក្រុមហ៊ុនដែលបានបង្កើតឡើងនៅសហរដ្ឋអាមេរិក ជាក្រុមហ៊ុនកាន់កាប់ផ្ទាល់ និងជាក្រុមហ៊ុនមេរបស់ក្រុមហ៊ុនរៀងៗខ្លួន។

### ព្រឹត្តិការណ៍សំខាន់ៗអំឡុងការិយបរិច្ឆេទ

ព័ត៌មានលម្អិតនៃព្រឹត្តិការណ៍សំខាន់ៗអំឡុងការិយបរិច្ឆេទ ត្រូវបានបង្ហាញនៅកំណត់សម្គាល់ ៣០ នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងការិយបរិច្ឆេទ

ព័ត៌មានលម្អិតនៃព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងការិយបរិច្ឆេទ ត្រូវបានបង្ហាញនៅកំណត់សម្គាល់ ៣១ នៃរបាយការណ៍ហិរញ្ញវត្ថុ។

### សវនករ

សវនករ Messrs. បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក បានបញ្ជាក់ពីឆន្ទៈដើម្បីបន្តការងារនេះ។

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើអំណះអំណាងថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

ក) អនុម័តគោលការណ៍គណនេយ្យសមស្រប ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRSs) ដោយពឹងផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនោះឱ្យមានសង្គតភាព។

ខ) អនុលោមតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន ដែលអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRSs) ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដាទាំងនេះ ក្នុងការបង្ហាញនូវភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីក្រុមហ៊ុនអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព។

**អរ អិម អេ (ខេមបូឌា) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយប្រើប្រាស់មូលដ្ឋាននិរន្តរភាព លុះត្រាតែវាមានភាពមិនត្រឹមត្រូវក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តកិច្ចប្រតិបត្តិការរបស់ខ្លួននាពេលអនាគត និង

ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាពតាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញនៅទំព័រទី៦ ដល់ ទី៦៦ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។

ចុះហត្ថលេខាជំនួសក្រុមប្រឹក្សាភិបាល

.....................................................................

**ជន សាំង**

នាយកប្រតិបត្តិ

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១

**អ អិម អេ (ខេមបូឌា) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ពាន់រៀល | ២០១៩ ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ២០១៩ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|---|---|
| ចំណូល | ៥ | ២៩៣.១៧៩.៤៥៤ | ១.១៩៥.២៩២.៨៩៧ | ២៨៣.៤៦១.៣៤១ | ១.១៤៨.៥៧៥.៣៥៤ |
| ថ្លៃដើម | | (២៤៦.៨៧៧.០០៧) | (១.០០៦.៥១៧.៦៥៨) | (២៣៧.០៧៥.៨៤៣) | (៩៦០.៦៣១.៥១៨) |
| **ចំណេញដុល** | | ៤៦.៣០២.៤៤៧ | ១៨៨.៧៧៥.២៣៩ | ៤៦.៣៨៥.៤៩៨ | ១៨៧.៩៤៣.៨៣៦ |
| ចំណូលផ្សេងៗ | ៦ | ១.៣១១.៤៤៧ | ៥.៣៤៦.៧៦៩ | ៨៥២.០៥៥ | ៣.៤៥២.៨៤៣ |
| ចំណាយប្រតិបត្តិការ | | (៧.២៤៦.១៣៦) | (២៩.៥៤៦.៣៤៦) | (៩.៣៧២.៥១២) | (៣៧.៩៧៧.៤១៥) |
| ចំណាយទីផ្សារ | | (១.១៣៦.៦៦៨) | (៤.៦៣៤.១៩៥) | (៩០២.២០៦) | (៣.៦៥៥.៧៣៥) |
| ចំណាយរដ្ឋបាល | | (៨.៤៧៨.២៤២) | (៣៤.៥៦២.១០៦) | (៦.៦០៩.៣០៧) | (២៦.៧៥០.៥១៣) |
| **ចំណេញប្រតិបត្តិការ** | | ៣០.៧៥២.៨៤៨ | ១២៥.៣៧៩.៣៦១ | ៣០.៣៥៣.៤៨២ | ១២២.៩៩២.៣០៨ |
| ចំណាយហិរញ្ញវត្ថុ | | (៣.៦២៤.៦៣២) | (១៤.៧៧៧.៦២៨) | (២.៣៦៧.៨៩០) | (៩.៥៩៤.៦៨៧) |
| **ចំណេញមុនបង់ពន្ធ** | ៧ | ២៧.១២៨.២១៦ | ១១០.៦០១.៧៣៣ | ២៧.៩៨៥.៥៩២ | ១១៣.៣៩៧.៦២១ |
| ពន្ធលើប្រាក់ចំណូល | ៨ | (៣.៣២១.៩៤៦) | (១៣.៥៤៣.៥៧០) | (៥.៦១៩.១៣៥) | (២២.៧៦៨.៧៣៨) |
| **ចំណេញប្រចាំឆ្នាំ** | | ២៣.៨០៦.២៧០ | ៩៧.០៥៨.១៦៣ | ២២.៣៦៦.៤៥៧ | ៩០.៦២៨.៨៨៣ |
| **លទ្ធផលលម្អិតផ្សេងៗក្រោយបង់ពន្ធ** | | | | | |
| *ចំណូលដែលអាចត្រូវបានចាត់ថ្នាក់ឡើងវិញក្រោយពីចំណេញ ឬខាត* | | | | | |
| ការប្តូររូបិយប័ណ្ណបរទេស | | - | (១.៤៦០.៧៦៧) | - | ១.០៧៦.៦២១ |
| **លទ្ធផលចំណូលលម្អិតប្រចាំឆ្នាំ** | | ២៣.៨០៦.២៧០ | ៩៥.៥៩៧.៣៩៦ | ២២.៣៦៦.៤៥៧ | ៩១.៧០៥.៥០៤ |

កំណត់សម្គាល់នៅទំព័រទី ១៦ ទៅ ៦៦ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**អេ អិម អេ (ខេមបូឌា) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ពាន់រៀល | ២០១៩ ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ២០១៩ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ១០ | ៩.៣៨២.៥៣០ | ៣៧.៩៥២.៣៣៤ | ៨.៩២៨.៤៣១ | ៣៦.៣៨៣.៣៥៦ |
| សិទ្ធក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ១១ | ៣.៦៤១.៥៦៤ | ១៤.៧៣០.១២៦ | ៣.៨១៥.១៩៩ | ១៥.៥៤៦.៩៣៦ |
| ទ្រព្យសកម្មពន្ធពន្យារ, សុទ្ធ | ១២ | ៣.១៩០.៩០៤ | ១២.៩០៧.២០៨ | ៩៤៨.៦៣៥ | ៣.៨៦៤.៧០០ |
| ទ្រព្យសកម្មអរូបី | ១៣ | - | - | - | - |
| | | ១៦.២១៤.៩៩៨ | ៦៥.៥៨៩.៦៦៨ | ១៣.៦៩២.២៦៥ | ៥៥.៧៩៤.៩៩២ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិ | ១៤ | ៣៧.៨១៤.១១៥ | ១៥២.៩៥៨.០៩៧ | ៧៥.២២២.២២១ | ៣០៦.៥៣០.៥៤១ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ១៥ | ៧.០៥៣.៤៩០ | ២៨.៥៣១.៣៦៧ | ៨.៥៦៥.១៤០ | ៣៤.៩០២.៩៥៦ |
| ទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធ | ១៦ | ៣.១៣១.៨៩៣ | ១២.៦៦៨.៥០៧ | ១៣.២៤១.៩០៧ | ៥៣.៩៦០.៧៧១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៧ | ៣៩.៣៥២.៧៦៦ | ១៥៩.១៨១.៩៣៨ | ១០.៨៩៩.២១៩ | ៤៤.៤១៤.៣១៧ |
| | | ៨៧.៣៥២.២៦៤ | ៣៥៣.៣៣៩.៩០៩ | ១០៧.៩២៨.៤៨៧ | ៤៣៩.៨០៨.៥៨៥ |
| **ទ្រព្យសកម្មសរុប** | | ១០៣.៥៦៧.២៦២ | ៤១៨.៩២៩.៥៧៧ | ១២១.៦២០.៧៥២ | ៤៩៥.៦០៣.៥៧៧ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១៨ | ៨.៧៩៧.២៥៣ | ៣៥.៥៨៤.៨៨៨ | ១៥.៨១៦.៣១៩ | ៦៤.៤៥១.៥០០ |
| កិច្ចសន្យាបំណុល | ១៩ | ១៤.៥៩៤.៤៥០ | ៥៩.០៣៤.៥៥១ | ១៤.៦៤៥.៨៧៣ | ៥៩.៦៨១.៩៣២ |
| ទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនពាក់ព័ន្ធ | ១៦ | ៥៤៦.១៦៩ | ២.២០៩.២៥៤ | ៦.៨១៤.៩៨៩ | ២៧.៧៧១.០៨០ |
| សំវិធានធន | ២០ | ២.៣១៥.៤៤៦ | ៩.៣៦៥.៩៧៩ | ២.៣២១.៥៦០ | ៩.៤៦០.៣៥៧ |
| ឥណទាន និងប្រាក់កម្ចី | ២១ | ៧.៣៥៤.១២៧ | ២៩.៧៤៧.៤៤៤ | ៤៤.៧៦៣.២៦៦ | ១៨២.៤១០.៣០៩ |
| បំណុលភតិសន្យា | ២២ | ៦៤៤.១៥៤ | ២.៦០៥.៦០៣ | ៦៥៧.៩៣១ | ២.៦៨១.០៦៩ |
| បំណុលពន្ធ | | ៣.១៣៨.៦៧៦ | ១២.៦៩៥.៩៤៩ | ៣.៧៧៩.២៩៤ | ១៥.៤០០.៦២៣ |
| | | ៣៧.៣៩០.២៧៥ | ១៥១.២៤៣.៦៦៨ | ៨៨.៧៩៩.២៣២ | ៣៦១.៨៥៦.៨៧០ |
| **ទ្រព្យសកម្មរយៈពេលខ្លីសុទ្ធ** | | ៤៩.៩៦១.៩៨៩ | ២០២.០៩៦.២៤១ | ១៩.១២៩.២៥៥ | ៧៧.៩៥១.៧១៥ |

**អេ អិម អេ ( ខេមបូឌា ) ម.ក**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ត)

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ពាន់រៀល | ២០១៩ ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ២០១៩ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|---|---|
| **បំណុលរយៈពេលវែង** | | | | | |
| ឥណទាន និងប្រាក់កម្ចី | ២១ | ១៦.០៣៩.៣១២ | ៦៤.៨៧៩.០១៧ | - | - |
| បំណុលភតិសន្យា | ២២ | ៣.២៣៨.២៧៩ | ១៣.០៩៨.៨៣៩ | ៣.៣២៨.៣៩៤ | ១៣.៥៦៣.២០៦ |
| | | ១៩.២៧៧.៥៩១ | ៧៧.៩៧៧.៨៥៦ | ៣.៣២៨.៣៩៤ | ១៣.៥៦៣.២០៦ |
| **បំណុលសរុប** | | ៥៦.៦៦៧.៨៦៦ | ២២៩.២២១.៥២០ | ៩២.១២៧.៦២៦ | ៣៧៥.៤២០.០៧៦ |
| **ទ្រព្យសកម្មសុទ្ធ** | | ៤៦.៨៩៩.៣៩៦ | ១៨៩.៧០៨.០៥៧ | ២៩.៥៤៣.១២៦ | ១២០.២០៣.៨៦១ |
| **ដើមទុន និងបម្រុង** | | | | | |
| ដើមទុន | ២៣ | ៤.០០០.០០០ | ១៦.០០០.០០០ | ៤.០០០.០០០ | ១៦.០០០.០០០ |
| ចំណេញរក្សាទុក | | ៤២.៨៩៩.៣៩៦ | ១៧៤.៣១៣.៨០០ | ២៥.៥៤៣.១២៦ | ១០៣.៣៤៨.៨៣៧ |
| ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ | ២៤ | - | (៦០៥.៧៤៣) | - | ៨៥៥.០២៤ |
| **មូលធនសរុប** | | ៤៦.៨៩៩.៣៩៦ | ១៨៩.៧០៨.០៥៧ | ២៩.៥៤៣.១២៦ | ១២០.២០៣.៨៦១ |

កំណត់សម្គាល់នៅទំព័រទី ១៦ ទៅ ៦៦ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## អេ អិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | មូលធនភាគហ៊ុន ដុល្លារអាមេរិក | ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | មូលធនសរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ដូចបានរាយការណ៍ពីមុន** | | ៤.០០០.០០០ | - | ១០.៦២៦.៦៦៩ | ១៤.៦២៦.៦៦៩ |
| ចំណេញ និងសរុបលទ្ធផលលម្អិតផ្សេងៗប្រចាំឆ្នាំ | | - | - | ២១.៤១៧.៨២២ | ២១.៤១៧.៨២២ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ភាគលាភ | ២៥ | - | - | (៧.៥០០.០០០) | (៧.៥០០.០០០) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដូចបានរាយការណ៍ពីមុន និងនាថ្ងៃទី១ ខែមករា ឆ្នាំ២០២០** | | ៤.០០០.០០០ | - | ២៤.៥៤៤.៤៩១ | ២៨.៥៤៤.៤៩១ |
| ផលប៉ះពាល់នៃកំណែកំហុសឆ្គង | ៣២ | - | - | ៩៤៨.៦៣៥ | ៩៤៨.៦៣៥ |
| **សមតុល្យកំណត់ឡើងវិញ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងនាថ្ងៃទី១ ខែមករា ឆ្នាំ២០២០** | | ៤.០០០.០០០ | - | ២៥.៤៩៣.១២៦ | ២៩.៤៩៣.១២៦ |
| ចំណេញ និងសរុបលទ្ធផលលម្អិតផ្សេងៗប្រចាំឆ្នាំ | | - | - | ២៣.៤០៦.២៧០ | ២៣.៤០៦.២៧០ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ភាគលាភ | ២៥ | - | - | (៦.៤០០.០០០) | (៦.៤០០.០០០) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | | ៤.០០០.០០០ | - | ៤២.៤៩៩.៣៩៦ | ៤៦.៤៩៩.៣៩៦ |
| **សមតុល្យកំណត់ឡើងវិញ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ (ពាន់រៀល)** | | ១៦.០០០.០០០ | ៨៥៥.០២៤ | ១០៣.៣៤៨.៤៣៧ | ១២០.២០៣.៤៦១ |
| **សមតុល្យ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ពាន់រៀល)** | | ១៦.០០០.០០០ | (៦០៥.៧៤៣) | ១៧៤.៣១៣.៨០០ | ១៨៩.៧០៨.០៥៧ |

កំណត់សម្គាល់នៅទំព័រទី ១០ ទៅ ៦៦ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**អេ អិម អេ (ខេមបូឌា) ម.ក**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ពាន់រៀល | ២០១៩ ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ២០១៩ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|---|---|
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញសុទ្ធមុនបង់ពន្ធ | | ២៧.១២៨.២១៦ | ១១០.៦០១.៨៣៧ | ២៧.៩៨៥.៩៥២ | ១១៣.៣៩៧.៦១៨ |
| និយ័តកម្ម៖ | | | | | |
| រំលស់ទ្រព្យសកម្មអរូបី | | - | - | ៤.៧៧៦ | ១៩.៣៥២ |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ២.២១៥.២៥៩ | ៩.០៣១.៩៩១ | ១.៩៩៥.៦១៩ | ៨.០៨៦.២៥៨ |
| រំលស់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | | ៨៧៥.៣២២ | ៣.៥៦៨.៦៨៧ | ៨៦២.៩៩៩ | ៣.៤៩៦.៦៨៣ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | (៥៨.០៧៨) | (២៣៦.៧៨៤) | (៩៧.៤៩៨) | (៣៩៥.០៦២) |
| ខាតពីការថយចុះតំលៃនៃ គណនីអតិថិជនពាណិជ្ជកម្ម | | ៥៥២.៧៥៤ | ២.២៥៣.៧៤១ | ៥៩០.០៩៦ | ២.៣៩១.០៨៩ |
| ចំណាយការប្រាក់សុទ្ធ | | ៣.៤២២.២៣៨ | ១៣.៩៥២.៤១៨ | ១.៨៩៧.៨១៤ | ៧.៦៩០.១៩៥ |
| ចំនេញ(ខាត) ពីការប្តូររូបិយប័ណ្ណ មិនទាន់បានទទួលស្គាល់សុទ្ធ | | (៤៣៣) | (១.៧៦៥) | (៤.៧៩៣) | (១៩.៤២១) |
| (ក្រលប់)ឬសំវិធានធនលើសន្និធិយឺត | | (២៧១.៤៥២) | (១.១០៦.៨៣២) | ១.៥៦៤.៩៩៨ | ៦.៣៣៩.១៤៣ |
| ការលុបចោលនៃ៖ | | | | | |
| - ទ្រព្យសកម្មអរូបី | | - | - | ១៥.២១៨ | ៦០.៥៦៨ |
| **ចំណេញប្រតិបត្តិការ មុនបំរែបំរួលដើមទុនបង្វិល** | | **៣៣.៨៦៣.៨៣១** | **១៣៨.០៣៤.៨២៥** | **៣៤.៨១៤.២៦៣** | **១៤១.០៦៦.៧១៣** |
| ថយចុះឬ(កើនឡើង) នៃសន្និធិ | | ៣៧.៦៧៩.៨៨៨ | ១៥៣.៦១៩.៦៨០ | (៤៥.៣៣០.៨៦០) | (១៨៣.៦៧៩.៤២៥) |
| ថយចុះឬ(កើនឡើង) នៃគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | | ៩៨៨.៧៣១ | ៤.០៣១.២១៩ | (២.៤៤៧.៩២៧) | (៩.៩១៧.៣៧៩) |
| ថយចុះឬ(កើនឡើង) នៃទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធ | | ៦.៣៦៣.៦៦២ | ២៥.៩៤៤.៦៦០ | (១.៧១៣.១៣២) | (៦.៩៤១.៦១១) |
| (ថយចុះ)ឬកើនឡើង នៃគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | | (៧.០១៨.៦៤៣) | (២៨.៦១៥.០០៨) | ៧.៧៦៧.៨៦៧ | ៣១.៤៧៥.៣៩៧ |
| (ថយចុះ)ឬកើនឡើង នៃកិច្ចសន្យាបំណុល | | (៥១.៤២៣) | (២០៩.៦៦២) | ៩.៥៤២.៨១០ | ៣៨.៦៦៧.៤៦៦ |
| (ថយចុះ)ឬកើនឡើង នៃសំវិធានធន | | (៦.១១៨) | (២៤.៩៤៧) | ៩៥៩.៨៥៦ | ៣.៨៨៩.៣៣៧ |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | **៧១.៨១៩.៦៧២** | **២៩២.៨៨០.៧៩១** | **៣.៩៩៣.៩៧៧** | **១៦.១៨០.៩៩៩** |
| ការប្រាក់ទទួលបាន | | ១៧២.៤៧៥ | ៧០៣.១៩៧ | ៣៩៩.៨២២ | ១.៦១៩.៨៦២ |
| ការប្រាក់បានបង់ | | (២.៦១៧.៩២៨) | (១០.៦៧៣.២៨៦) | (២.៣១៦.៤៤៤) | (៩.៣៨៧.៤៥២) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (៦.២០៤.៨២៣) | (២៥.២៩៧.០៦៣) | (៣.៤៣៩.៨០៥) | (១៣.៩៣៨.០៩០) |
| **សាច់ប្រាក់សុទ្ធបានពី ឬ(ប្រើប្រាស់ក្នុង) សកម្មភាពប្រតិបត្តិការ** | | **៦៣.១៦៩.៤០០** | **២៥៧.៥១៣.៦៣៣** | **(១.៣៦៣.៤៥០)** | **(៥.៥២៤.៨៥៦)** |

# អេ អឹម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ត)

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ពាន់រៀល | ២០១៩ ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ២០១៩ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|---|---|
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | (៤.៦៦៨.៧៨៤) | (១៩.០៣៤.៦៣២) | (៤.៩៦៧.៤០៤) | (២០.១២៨.៥២១) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ២.០៥៧.៥០៥ | ៨.៣៨៨.៤៤៨ | ១.៣៥៥.៣៨៦ | ៥.៤៩២.០២៤ |
| បម្រែបម្រួលនៃប្រាក់បញ្ញើធានា | | (១.០៨១.៨៧៥) | (៤.៣៧៦.២០១) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(៣.៦៩៣.១៥៤)** | **(១៥.០២២.៣៨៥)** | **(៣.៦១២.០១៨)** | **(១៤.៦៣៦.៤៩៧)** |
| **សកម្មភាពហិរញ្ញប្បទាន** | (ក) | | | | |
| មូលបត្រសុទ្ធទទួលបានពីការបោះផ្សាយមូលបត្រសាធារណៈ | | ១៨.៧៨៥.៣៦៩ | ៧៦.៥៩២.៦៤៧ | - | - |
| សាច់ប្រាក់ទទួលបានពីឥណទាន និងប្រាក់កម្ចី | | ១៤០.៧៣៨.៤០០ | ៥៧៣.៧៥០.៤៥៧ | ២៦៣.២៤៧.៧៦៥ | ១.០៦៦.៨៨២.៥៦០ |
| បង់សងរបស់ឥណទាន និងប្រាក់កម្ចី | | (១៨១.៩៩៤.៣២៧) | (៧៤១.៨០៣.១៧១) | (២៤៨.១២១.៦០១) | (១.០០៥.៣៨៥.៥៣៨) |
| បង់សងរបស់ទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនកាន់កាប់ផ្ទាល់ | | - | - | (១៩៥.៨៧៣) | (៦៣១.៥៥៧) |
| បង់សងរបស់បំណុលភតិសន្យា | | (៧៨៨.០៤៧) | (៣.០៩៩.៧៨៨) | (៨៥៥.៨៥១) | (៣.៦៣០.១៥០) |
| បង់ភាគលាភ | | (៨.៦៤០.០០០) | (៣៦.៦១១.៤៥០) | (៦.៨៤០.០០០) | (២៧.៧២៣.៧៥០) |
| **សាច់ប្រាក់សុទ្ធ (ប្រើប្រាស់ក្នុង) ឬបានពីសកម្មភាពហិរញ្ញប្បទាន** | | **(៣២.១០៤.៥៧៨)** | **(១៣១.៤៨១.៣០៥)** | **៧.២៧៤.២០៤** | **២៩.៥០៧.៥២៥** |
| **កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ២៧.៣៧១.៦៦៨ | ១១០.៨៩៨.៤៥១ | ១.៨៦៨.៦៣៦ | ៧.៧២៧.៤០២ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ** | | ១០.៨៦៩.២១៩ | ៤៤.៤១៦.៣១៧ | ៩.០០០.៥៨៣ | ៣៦.១៦៤.៣៨២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៥០៨.៤៣៥) | - | ៥២៤.៥៣៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | ១៧ | **៣៨.២៤០.៨៨៧** | **១៥៤.៨០៦.៣៣៣** | **១០.៨៦៩.២១៩** | **៤៤.៤១៦.៣១៧** |

កំណត់សម្គាល់នៅទំព័រទី ១៦ ទៅ ៦៦ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## អេ អិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## គោលការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ត)

(ក) ការផ្ទៀងផ្ទាត់បំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន

| | គណនាន និងប្រាក់កម្ចី ដុល្លារអាមេរិក | បំណុលភតិសន្យា ដុល្លារអាមេរិក | ទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនកាន់កាប់ផ្ទាល់ ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល |
|---|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ៤៤.៧៦៣.២៦៦ | ៣.៩៨៦.៣២៥ | ២.៥៨០.០០០ | ២៥.៤៩៣.១២៦ | ៧៥.៨៧៤.០៨២ | ៣០៦.០៣៦.០៣៦ |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | | |
| មូលបត្រសុទ្ធទទួលបានពី ការបោះផ្សាយបំណុលសាធារណៈ | ១៨.៧៩៥.៣៦៩ | - | - | - | ១៨.៧៩៥.៣៦៩ | ៧៦.៥៦២.៦៤៧ |
| សាច់ប្រាក់ទទួលបានពីគណនាន និងប្រាក់កម្ចី | ១៤០.៧៣៨.៨០០ | - | - | - | ១៤០.៧៣៨.៨០០ | ៥៧៣.៧៥០.៤៥៧ |
| បង់ត្រលប់គណនាន និងប្រាក់កម្ចី | (១៨១.៩៥៤.៣២៧) | - | - | - | (១៨១.៩៥៤.៣២៧) | (៧៤១.៥៥៣.១៧១) |
| បង់ត្រលប់បំណុលភតិសន្យា | - | (៧៤៨.០៤៧) | - | - | (៧៤៨.០៤៧) | (៣.០៤៥.៧៨៨) |
| បង់ភាគលាភ | - | - | (២.៥៨០.០០០) | (៦.៤០០.០០០) | (៨.៩៨០.០០០) | (៣៦.៦១១.៤៦០) |
| សាច់ប្រាក់សុទ្ធបានពី ឬប្រើប្រាស់ក្នុង) សកម្មភាពហិរញ្ញប្បទាន | (២២.៣៧៦.៤៣១) | (៧៤៨.០៤៧) | (២.៥៨០.០០០) | (៦.៤០០.០០០) | (៣២.១០៤.៤៧៨) | (១៣១.៤៥៩.៣០៥) |

**អេ អិម អេ (ខេមបូឌា) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍លំហូរសាច់ប្រាក់**

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ត)

(ក) ការផ្ទៀងផ្ទាត់បំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន (ត)

| | ឥណទាន និងប្រាក់កម្ចី ដុល្លារអាមេរិក | បំណុលភតិសន្យា ដុល្លារអាមេរិក | ទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនកាន់កាប់ផ្ទាល់ ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល |
|---|---|---|---|---|---|---|
| **បម្រែបម្រួលផ្សេងៗដែលពាក់ព័ន្ធនឹងបំណុល** | | | | | | |
| ភតិសន្យាបន្ថែម | - | ៣១១.៧៣៣ | - | - | ៣១១.៧៣៣ | ១.២៦០.៩៥៩ |
| ចំណាយការប្រាក់ | ១.០០៦.៧០៤ | ៣៣២.៤២២ | - | - | ១.៣៣៩.១២៦ | ៥.៤៥៩.៦១៧ |
| **សរុបបម្រែបម្រួលផ្សេងៗដែលពាក់ព័ន្ធនឹងបំណុល** | ១.០០៦.៧០៤ | ៦៤៤.១៥៥ | - | - | ១.៦៥០.៨៥៩ | ៦.៧២០.៥៧៦ |
| **បម្រែបម្រួលផ្សេងៗដែលពាក់ព័ន្ធនឹងមូលធន** | - | - | - | ២៣.៨០៦.២៧០ | ២៣.៨០៦.២៧០ | ៩៧.០៥៨.១៦៣ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | ២៣.៣៩៣.៨៣៩ | ៣.៨៨៧.៤៣៣ | - | ៤១.៩៤៥.៣៦១ | ៦៩.២២៦.៦៣៣ | ២៧៨.៣២៣.៤៧០ |

## អេ ម៉ិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ត)

(ក) ការផ្ទៀងផ្ទាត់ចំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន (ត)

| | ឥណទាន និងប្រាក់កម្ចី ដុល្លារអាមេរិក | ចំណុលគតិសន្យា ដុល្លារអាមេរិក | ទឹកប្រាក់ជំពាក់ទៅ ក្រុមហ៊ុនកាន់កាប់ផ្ទាល់ ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល |
|---|---|---|---|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ២៩.៥៨៧.២៩៨ | - | ២.០៥៥.៨៧៣ | ១០.៦២៦.៦៦៩ | ៤២.២៦៦.៨៤០ | ១៦៦.៩៦០.៧៥៧ |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | | |
| សាច់ប្រាក់ទទួលបានពីឥណទាន និងប្រាក់កម្ចី | ២៦៣.២៩៧.៧៦៩ | - | - | - | ២៦៣.២៩៧.៧៦៩ | ១.០៦៦.៨៨២.៨៦០ |
| បង់ត្រលប់ឥណទាន និងប្រាក់កម្ចី | (២៤៨.១២១.៨០១) | - | - | - | (២៤៨.១២១.៨០១) | (១.០០៥.៣៨៩.៨៣៨) |
| បង់ត្រលប់ទឹកប្រាក់ជំពាក់ទៅ ក្រុមហ៊ុនកាន់កាប់ផ្ទាល់ | - | - | ២.៨៤៤.១២៧ | (៣.០០០.០០០) | (១៥៥.៨៧៣) | (៦៣១.៥៥៧) |
| បង់ចំណុលគតិសន្យា | - | (៧៩៥.៨៩១) | - | - | (៧៩៥.៨៩១) | (៣.២៣០.១៦០) |
| បង់ភាគលាភ | - | - | (២.៣៥០.០០០) | (៤.៦០០.០០០) | (៦.៩៥០.០០០) | (២៧.៧២៣.៧៥០) |
| សាច់ប្រាក់សុទ្ធបានពី ឬ(ប្រើប្រាស់ក្នុង) សកម្មភាពហិរញ្ញប្បទាន | ១៥.១៧៥.៩៦៨ | (៧៩៥.៨៩១) | ៤៩៤.១២៧ | (៧.៦០០.០០០) | ៧.២៧៤.២០៤ | ២៩.៥០៧.៥២៥ |

# អេ អិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ត)

(ក) ការផ្ទៀងផ្ទាត់បំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន (ត)

| | ឥណទាន និងប្រាក់កម្ចី ដុល្លារអាមេរិក | បំណុលភតិសន្យា ដុល្លារអាមេរិក | ទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនកាន់កាប់ផ្ទាល់ ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល |
|---|---|---|---|---|---|---|
| បម្រែបម្រួលផ្សេងៗដែលពាក់ព័ន្ធនឹងបំណុល | | | | | | |
| ភតិសន្យាថ្មី | - | ៤.៥៤៥.៦៨២ | | - | ៤.៥៤៥.៦៨២ | ១៨.៥៣៧.៧៨៦ |
| ចំណាយការប្រាក់ | - | ៣៣៦.៥៣៤ | - | - | ៣៣៦.៥៣៤ | ១.៣៧២.០៤៥ |
| ផលប៉ះពាល់នៃកំណែកំហុសឆ្គង | - | - | - | ៩៤៨.៦៣៥ | ៩៤៨.៦៣៥ | ៣.៨៦៤.៦៦០ |
| សរុបបម្រែបម្រួលផ្សេងៗដែលពាក់ព័ន្ធនឹងបំណុល (កំណត់ឡើងវិញ) | - | ៤.៨៨២.២១៦ | - | ៩៤៨.៦៣៥ | ៥.៨៣០.៨៥១ | ២៣.៧៧៤.៤៩១ |
| បម្រែបម្រួលផ្សេងៗដែលពាក់ព័ន្ធនឹងមូលធន | - | - | - | ២១.៤១៧.៨២២ | ២១.៤១៧.៨២២ | ៨៧.៣២០.៤៩០ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ (កំណត់ឡើងវិញ) | ៤៤.៧៦៣.២៦៦ | ៣.៧៥៦.៣២៥ | ២.៥៥០.០០០ | ២៥.៤៥៣.១២៦ | ៧៦.៥២២.៧១៧ | ៣១០.៥៧៨.១៩៧ |

កំណត់សម្គាល់នៅទំព័រទី ១៦ ទៅ ៦៦ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

### ១. ព័ត៌មានអំពីក្រុមហ៊ុន

អ អិម អេ (ខេមបូឌា) ម.ក (“ក្រុមហ៊ុន”) ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជី និងមានទីស្នាក់ការនៅព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យចុះបញ្ជី និងអាសយដ្ឋានអាជីវកម្មរបស់ក្រុមហ៊ុនស្ថិតនៅផ្ទះលេខ២៧E១ ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការធ្វើសកម្មភាពលក់យានយន្ត គ្រឿងបន្លាស់ គ្រឿងចក្រធុនធ្ងន់ និងការផ្តល់សេវាកម្មជួសជុល និងថែទាំ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្រុមប្រឹក្សាភិបាលបានចាត់ទុកក្រុមហ៊ុនកាន់កាប់ផ្ទាល់ និងក្រុមហ៊ុនមេរបស់ខ្លួនគឺមានក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនបានបង្កើតឡើងក្នុងទីក្រុងហុងកុង និងក្រុមហ៊ុន Whitbro LLC ដែលជាក្រុមហ៊ុនបានបង្កើតឡើងនៅសហរដ្ឋអាមេរិករៀងៗគ្នា។

### ២. គោលនយោបាយគណនេយ្យសំខាន់ៗ

#### (ក) មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន បានរៀបចំឡើងអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRSs)។ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន បានរៀបចំតាមវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានបង្ហាញផ្សេងពីនេះនៅក្នុងគោលនយោបាយគណនេយ្យសំខាន់ៗ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ស្របតាមស្តង់ដារ CIFRSs តម្រូវឱ្យអ្នកគ្រប់គ្រងប្រើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតពីការអនុវត្តគោលនយោបាយ និងចំនួនទឹកប្រាក់ដែលត្រូវបានរាយការណ៍ពីទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ។ ការប៉ាន់ស្មាន និងការសន្មតនេះត្រូវពឹងផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្រ និងកត្តាផ្សេងៗទៀតជាច្រើន ដែលត្រូវបានជឿជាក់ថាសមហេតុផលក្នុងកាលៈទេសៈណាមួយ លទ្ធផលដែលបង្កើតជាមូលដ្ឋានសម្រាប់ធ្វើការវិនិច្ឆ័យអំពីតម្លៃយោងទ្រព្យសកម្ម និងបំណុលមិនបានបង្ហាញជាក់ស្តែងតាមប្រភពផ្សេងៗនោះទេ។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការសន្មតទាំងនេះ។

មូលដ្ឋាននៃការប៉ាន់ស្មាន និងការសន្មតត្រូវបានពិនិត្យឡើងវិញជាប្រចាំ។ កំណែសម្រួលគណនេយ្យប៉ាន់ស្មាន ត្រូវបានទទួលស្គាល់នៅក្នុងរយៈពេលដែលការប៉ាន់ស្មានត្រូវបានកែសម្រួល ប្រសិនបើការកែសម្រួលនេះប៉ះពាល់តែក្នុងរយៈពេលនោះ ឬក៏ក្នុងអំឡុងពេលកែសម្រួល និងត្រូវទទួលស្គាល់នៅពេលអនាគត ប្រសិនបើការកែសម្រួលនោះប៉ះពាល់ទាំងបច្ចុប្បន្ន និងអនាគត។

ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៤។

## ២. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ខ) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយប័ណ្ណជាតិនៃប្រទេសកម្ពុជា គឺប្រាក់រៀល។ ប៉ុន្តែក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងរក្សាកំណត់ត្រាបញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក គ្រប់គ្រងក៏បានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន ដែលប្រើប្រាស់សម្រាប់ការវាស់វែង និងការធ្វើរបាយការណ៍ ដែលឆ្លុះបញ្ចាំងពីស្ថានភាពព្រឹត្តិការណ៍សេដ្ឋកិច្ច និងកាលៈទេសៈរបស់ក្រុមហ៊ុន។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺស្របតាមតម្រូវការនៃច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម ហើយអត្រាប្តូរប្រាក់ផ្លូវការ និងអត្រាប្តូរប្រាក់មធ្យមដែលបានប្រើប្រាស់ ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៨៩ រៀល និង ៤.០៧៧ រៀល រៀងៗខ្លួនសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (២០១៩: ៤.០៧៥ រៀល និង៤.០៥២ រៀល) គឺដូចបានប្រកាសដោយធនាគារជាតិនៃកម្ពុជា។

ការប្តូរប្រាក់នេះ មិនគួរត្រូវបានបកស្រាយថាជាតំណាងដែលចំនួនទឹកប្រាក់ដុល្លារអាមេរិកត្រូវបាន អាចត្រូវបាន ឬនឹងប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ដទៃទៀតឡើយ។

### (គ) ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងអស់ ត្រូវបានទទួលស្គាល់ជាដំបូងនៅថ្លៃដើម ហើយបន្ទាប់មកដោយថ្លៃដើមដករំលស់បង្គរ និងការថយចុះតម្លៃបង្គរ។ ថ្លៃដើមនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដែលត្រូវបានទទួលស្គាល់រួមមាន ថ្លៃទិញ និងថ្លៃដើមណាមួយដែលបាននាំទ្រព្យសកម្មទៅទីតាំង និងលក្ខខណ្ឌចាំបាច់ដើម្បីឲ្យវាមានសមត្ថភាពធ្វើប្រតិបត្តិការដូចដែលបានកំណត់ដោយអ្នកគ្រប់គ្រង។

ចំណាយនៃការផ្លាស់ប្តូរផ្នែកណាមួយនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់នៅតម្លៃយោងនៃទ្រព្យសកម្មប្រសិនបើមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ នឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយចំណាយទាំងនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់ចំពោះ។ តម្លៃយោងនៃផ្នែកដែលត្រូវបានផ្លាស់ប្តូរ ត្រូវបានលុបកត់ត្រា។

ថ្លៃដើមនៃការរុះរើ ការយកចេញ ឬការតំឡើងត្រូវបានរាប់បញ្ចូលជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ប្រសិនបើកាតព្វកិច្ចរុះរើ ដកចេញ ឬការតំឡើង កើតឡើងដោយសារការទទួល ឬការប្រើប្រាស់ទ្រព្យសកម្មនោះ។

ចំពោះទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដែលបានលក់ចោល ភាពខុសគ្នារវាងសាច់ប្រាក់ដែលបានពីការលក់ និងតម្លៃយោងនឹងត្រូវកត់ត្រាទៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត។

ទ្រព្យសកម្មកំពុងសាងសង់ ដែលរួមបញ្ចូលក្នុងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ មិនត្រូវបានយកមកធ្វើរំលស់ទេ ដោយសារតែទ្រព្យសកម្មទាំងនោះមិនទាន់អាចប្រើប្រាស់បាន។

## ២. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (គ) ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

ការរំលស់ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីទូទាត់ថ្លៃដើមទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងអស់លើអាយុកាលប្រើប្រាស់រំពឹងទុក។ អាយុកាលប្រើប្រាស់រំពឹងទុកមានដូចខាងក្រោម៖

| | ឆ្នាំ |
|---|---|
| អគារ | ១០ - ៥០ |
| ឧបករណ៍សម្រាប់សេវាកម្ម និងបរិក្ខារឃ្លាំង | ៥ |
| សង្ហារឹម និងបរិក្ខារបំពាក់ | ៤ |
| ការកែលម្អ | ៥ - ១០ |
| យានយន្ត | ៥ |
| ឧបករណ៍សម្រាប់ប្រតិបត្តិការ | ៣ - ៥ |
| កុងតឺន័រ | ៤ |

តម្លៃសំណល់ អាយុកាលប្រើប្រាស់រំពឹងទុក និងវិធីសាស្ត្ររំលស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើនិយ័តកម្មតាមការសមស្របនៅរៀងរាល់ចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗ។ ផលប៉ះពាល់នឹងត្រូវទទួលស្គាល់ទៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាតនៅពេលដែលមានការកែ សម្រួលកើតឡើង។

ទ្រព្យសកម្មដែលបានរំលស់ពេញលេញនឹងត្រូវរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ រហូតដល់វាប្រើប្រាស់លែងបាន។

### (ឃ) ភតិសន្យា

នៅកាលបរិច្ឆេទចាប់ផ្តើមជួល ក្រុមហ៊ុនវាយតម្លៃថាតើកិច្ចសន្យាគឺជា ឬមានលក្ខណៈ ជាកិច្ចសន្យាជួលឬទេ។ កិច្ចព្រមព្រៀងគឺជា ឬមានលក្ខណៈ ឬជាកិច្ចសន្យាជួល ប្រសិនបើកិច្ចសន្យានោះបានផ្តល់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មក្នុងរយៈពេលណាមួយ។

គោលការណ៍នេះត្រូវបានអនុវត្តចំពោះកិច្ចសន្យាណាដែលបានធ្វើ ផ្លាស់ប្តូរនៅ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩។

**ក្នុងនាមជាអ្នកជួល**

នៅពេលចាប់ផ្តើម ឬនៅពេលមានការកែប្រែកិច្ចសន្យាដែលមានសមាសធាតុភតិសន្យា ក្រុមហ៊ុនបែងចែកតម្លៃនៅក្នុងកិច្ចសន្យាទៅសមាសធាតុនីមួយៗ ដោយឈរលើមូលដ្ឋានដាច់ដោយឡែករបស់ពួកគេ។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ឃ) ភតិសន្យា (ត)

**ក្នុងនាមជាអ្នកជួល (ត)**

ក្រុមហ៊ុនបានទទួលស្គាល់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យានៅកាលបរិច្ឆេទចាប់ផ្តើមជួល។ សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់ដំបូងនៅថ្លៃដើម ដែលរួមមានទឹកប្រាក់ដំបូងនៃបំណុលភតិសន្យា ដែលត្រូវបានកែសម្រួលសម្រាប់ការទូទាត់ភតិសន្យានានា ដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើម បូករួមនឹងថ្លៃដើមផ្ទាល់ដំបូងផ្សេងទៀតដែលបានកើតឡើង និងថ្លៃដើមប៉ាន់ស្មានសម្រាប់ការរុះរើ និងដកចេញទ្រព្យសកម្ម ឬស្តារឡើងវិញនូវទ្រព្យសកម្ម ឬទីកន្លែងដែលទ្រព្យសកម្មតាំងនៅ ឬស្តារឡើងវិញនូវទ្រព្យសកម្មទៅតាមលក្ខខណ្ឌនៃភតិសន្យា លើកលែងតែការចំណាយទាំងនោះត្រូវបានកើតឡើងសំរាប់ការផលិតសន្និធិ ហើយដកទឹកប្រាក់បានទទួលជាការលើកទឹកចិត្តភតិសន្យា។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានរំលស់តាមខ្សែបន្ទាត់ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរចាប់ពីកាលបរិច្ឆេទចាប់ផ្តើមរហូតដល់ចុងបញ្ចប់នៃរយៈពេលជួល លើកលែងតែភតិសន្យាមានការផ្ទេរកម្មសិទ្ធនៃទ្រព្យសកម្មទៅអោយក្រុមហ៊ុននៅពេលចប់រយៈពេលជួល ឬក៏តម្លៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្មឆ្លុះបញ្ចាំងថាក្រុមហ៊ុននឹងអនុវត្តនូវជម្រើសទិញ។ អាយុកាលប្រើប្រាស់រំពឹងទុកនៃសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានដូចគ្នាទៅនឹងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ។ បន្ថែមពីនេះទៀត សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានកាត់បន្ថយជាទៀងទាត់ដោយការខាតបង់លើការថយចុះនៃតម្លៃបើមាន ហើយត្រូវបានកែតម្រូវសម្រាប់ការវាស់វែងឡើងវិញជាក់លាក់នៃបំណុលភតិសន្យា។

បំណុលភតិសន្យាត្រូវបានវាស់វែងដំបូងនៅតម្លៃបច្ចុប្បន្ននៃការជួល ដែលមិនទាន់បានបង់នៅកាលបរិច្ឆេទចាប់ផ្តើមធ្វើអប្បហារ ដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងកិច្ចសន្យាជួល ឬប្រសិនបើអត្រាការប្រាក់មិនអាចកំណត់បាន ជាទូទៅក្រុមហ៊ុននឹងប្រើអត្រាប្រាក់កម្ចីកើនឡើងរបស់ខ្លួនជាអត្រាអប្បហារ។

ការទូទាត់ភតិសន្យារួមបញ្ចូលទាំងការវាស់វែងបំណុលភតិសន្យា ត្រូវបានបង្ហាញដូចខាងក្រោម៖

- ការទូទាត់ថេរ រួមទាំងការទូទាត់រូបធាតុថេរ។
- ការទូទាត់ភតិសន្យាអថេរអាស្រ័យលើសន្ទស្សន៍ ឬអត្រាណាមួយដែលវាស់វែងដំបូងដោយប្រើសន្ទស្សន៍ ឬអត្រាមួយនៅកាលបរិច្ឆេទចាប់ផ្តើម។
- ទឹកប្រាក់រំពឹងថានឹងត្រូវបង់ក្រោមការធានាតម្លៃនៅសល់ និងតម្លៃអនុវត្តក្រោមជម្រើសនៃការទិញដែលក្រុមហ៊ុនបានអនុវត្តក្នុងហេតុផលសមរម្យ ការបន្តជួលក្នុងរយៈពេលថ្មី ប្រសិនបើក្រុមហ៊ុនមានហេតុផលជាក់លាក់ក្នុងការប្រើជម្រើសពន្យារពេល និងការពិន័យលើកលែងតែក្រុមហ៊ុនមានភាពប្រាកដសមហេតុផលថា នឹងមិនបញ្ចប់ភតិសន្យាមុន កាលកំណត់។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ឃ) ភតិសន្យា (ត)

**ក្នុងនាមជាអ្នកជួល (ត)**

បំណុលភតិសន្យាត្រូវបានវាស់វែងនៅថ្លៃដើមរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វាត្រូវបានវាស់វែងឡើងវិញនៅពេលដែលមានការផ្លាស់ប្តូរលើការទូទាត់ភតិសន្យានាពេលអនាគត ដែលកើតឡើងពីការផ្លាស់ប្តូរសន្ទស្សន៍ ឬអត្រា ប្រសិនបើមានការផ្លាស់ប្តូរការប៉ាន់ស្មានរបស់ក្រុមហ៊ុនអំពីចំនួនទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់ក្រោមតម្លៃធានានៅសល់ ឬប្រសិនបើក្រុមហ៊ុនធ្វើការផ្លាស់ប្តូរការវាយតំលៃថាតើក្រុមហ៊ុនគួរអនុវត្តជម្រើសទិញបន្ថែម ពន្យារ ឬបញ្ឈប់ឬទេ ឬប្រសិនបើមានការកែសម្រួលថ្លៃជួលភតិសន្យារថេរ។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់ឡើងវិញតាមវិធីនេះ៖ ការកែតម្រូវនឹងត្រូវធ្វើឡើងទៅលើតម្លៃយោងនៃសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ឬត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត ប្រសិនបើតម្លៃយោងនៃសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានកាត់បន្ថយទៅសូន្យ។

ក្រុមហ៊ុនធ្វើការបង្ហាញសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាដាច់ដោយឡែកពីគ្នានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

**ការជួលរយៈពេលខ្លី និងការជួលទ្រព្យសកម្មដែលមានតំលៃទាប**

ក្រុមហ៊ុនបានជ្រើសរើសមិនទទួលស្គាល់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាដែលបានជួលក្នុងរយៈពេលខ្លី និងការជួលទ្រព្យសកម្មដែលមានតម្លៃទាបទេ។ ក្រុមហ៊ុនទទួលស្គាល់ការជួលភតិសន្យាទាំងនេះ ជាចំណាយដោយផ្អែកលើមូលដ្ឋានថេរក្នុងរយៈពេលជួល។

### (ង) ការថយចុះតម្លៃនៃទ្រព្យសកម្ម

**ការខាតបង់ឥណទាន និងការថយចុះតម្លៃនៃទ្រព្យសកម្ម**

ក្រុមហ៊ុន ទទួលស្គាល់សំវិធានធនបាត់បង់សម្រាប់ការខាតបង់ឥណទានរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងនៅថ្លៃដើមរំលស់ (រួមទាំងគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធ និងសាច់ប្រាក់ និងសាច់ប្រាក់សមមូល) ។

**ការវាស់វែងការខាតបង់ឥណទានរំពឹងទុក**

ការខាតបង់ឥណទានរំពឹងទុក គឺជាការប៉ាន់ស្មានដោយផ្អែកលើប្រូបាបនៃការបាត់បង់ឥណទាន។ ការខាតបង់ឥណទាន ត្រូវបានវាស់វែងនៅតម្លៃបច្ចុប្បន្ននៃការខាតបង់សាច់ប្រាក់ដែលបានរំពឹងទុកទាំងអស់ (ឧទាហរណ៍ ភាពខុសគ្នារវាងលំហូរសាច់ប្រាក់យោងតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលក្រុមហ៊ុនរំពឹងថានឹងទទួលបាន) ។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ង) ការថយចុះតម្លៃនៃទ្រព្យសកម្ម (ត)

**ការវាស់វែងការខាតបង់ឥណទានរំពឹងទុក (ត)**

រយៈពេលអតិបរមា សម្រាប់ពិចារណានៅពេលធ្វើការប៉ាន់ស្មានការខាតបង់ឥណទានរំពឹងទុកគឺជារយៈពេលកិច្ចសន្យាអតិបរមាដែលក្រុមហ៊ុនត្រូវប្រឈមនឹងហានិភ័យឥណទាន។ ក្នុងការវាស់ស្ទង់ការខាតបង់ឥណទានរំពឹងទុក ក្រុមហ៊ុនត្រូវគិតពិចារណានូវព័ត៌មានសមហេតុផល និងអាចជឿជាក់បានដែលអាចរកបានដោយមិនបាច់ចំណាយថវិកា ឬការប្រឹងប្រែងហួសប្រមាណ។ នេះរួមបញ្ចូលទាំងព័ត៌មានអំពីព្រឹត្តិការណ៍កន្លងមក ស្ថានភាពបច្ចុប្បន្ន និងការព្យាករណ៍នៃស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត។

ដោយយោងទៅតាមលក្ខណៈនៃទ្រព្យសកម្មហិរញ្ញវត្ថុ ការវាយតម្លៃនៃការកើនឡើងជាសារវន្តនៃហានិភ័យឥណទានត្រូវបានអនុវត្តដោយផ្អែកលើមូលដ្ឋានបុគ្គល ឬជាសមូហភាព។ នៅពេលដែលការវាយតម្លៃជាមូលដ្ឋានសមូហភាពត្រូវបានអនុវត្ត ឧបករណ៍ហិរញ្ញវត្ថុត្រូវបានដាក់ជាក្រុមដោយពឹងផ្អែកលើចរិកលក្ខណៈហានិភ័យឥណទាន ដូចជាស្ថានភាពបំណុលហួសកាលកំណត់ និងចំណាត់ថ្នាក់ហានិភ័យឥណទាន។

ការខាតបង់ឥណទានរំពឹងទុក ត្រូវបានវាស់វែងឡើងវិញនៅកាលបរិច្ឆេទរាយការណ៍នីមួយៗដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរហានិភ័យឥណទានរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ចាប់តាំងពីការទទួលស្គាល់ដំបូង។ ទឹកប្រាក់ពីការផ្លាស់ប្តូរការខាតបង់ឥណទានរំពឹងទុក ត្រូវបានទទួលស្គាល់ជាការថយចុះតម្លៃចំណេញ ឬខាតនៅក្នុងរបាយការណ៍ចំណេញ ឬខាត។ ក្រុមហ៊ុនទទួលស្គាល់ការថយចុះតម្លៃចំណេញ ឬខាត ដោយការធ្វើនិយ័តកម្មតម្លៃយោងរបស់ខ្លួនតាមរយៈគណនីសំវិធានធនបាត់បង់។

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានការអន់ថយឥណទានឬទេ។ ទ្រព្យសកម្មហិរញ្ញវត្ថុមានការអន់ថយឥណទាន នៅពេលដែលមានព្រឹត្តិការណ៍មួយឬច្រើនធ្វើអោយមានការប៉ះទង្គិចខ្លាំងទៅលើលំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគត នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកើតឡើងនោះ។

ភស្តុតាងដែលធ្វើអោយទ្រព្យសកម្មហិរញ្ញវត្ថុមានការអន់ថយឥណទាន រួមមានព្រឹត្តិការណ៍ដែលអាចសង្កេតបានដូចខាងក្រោម៖

- ផលវិបាកហិរញ្ញវត្ថុជាសារវន្តរបស់កូនបំណុល
- បំពាននឹងកិច្ចសន្យា ដូចជាការខកខាន ឬមិនបានទូទាត់ការប្រាក់ ឬប្រាក់ដើមជំពាក់
- អ្នកខ្ចីប្រាក់អាចនឹងក្ស័យធន ឬការរៀបចំឡើងវិញនូវហិរញ្ញវត្ថុផ្សេងៗ
- ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងបរិយាកាសបច្ចេកវិទ្យា ទីផ្សារសេដ្ឋកិច្ច ឬបរិយាកាសច្បាប់ដែលជះឥទ្ធិពលអាក្រក់ដល់កូនបំណុល ឬ
- អសកម្មភាពនៃទីផ្សារមូលបត្រ ដោយសារតែផលលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកបោះផ្សាយលក់។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ង) ការថយចុះតម្លៃនៃទ្រព្យសកម្ម (ត)

**គោលនយោបាយលុបចេញពីបញ្ជី**

តម្លៃយោងដុលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានលុបចេញពីបញ្ជី (ទាំងផ្នែកខ្លះឬទាំងអស់) ដល់កម្រិតមួយដែលមិនអាចរំពឹងថានឹងអាចប្រមូលបានមកវិញ។ ជាទូទៅចំពោះករណីនេះ នៅពេលដែលក្រុមហ៊ុនកំណត់ថាកូនបំណុលមិនមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ដើម្បីសងចំនួនទឹកប្រាក់ដែលត្រូវបានលុបចេញពីបញ្ជី។

ការប្រមូលបានមកវិញនៃទ្រព្យសកម្មបន្ទាប់ពីបានលុបចេញពីបញ្ជី ត្រូវកត់ត្រាជាបញ្ច្រាសនៃការថយចុះនៃតម្លៃក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាតក្នុងរយៈពេលដែលការប្រមូលបានកើតឡើង។

**ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនធ្វើការវាយតម្លៃតម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ខ្លួនដើម្បីកំណត់ថា តើមានការបង្ហាញណាដែលថាទ្រព្យសកម្មទាំងនោះនឹងមានការបាត់បង់លើការថយចុះនៃតម្លៃទ្រព្យសកម្មដែរឬទេ។ ប្រសិនបើមានការចង្អុលបង្ហាញបែបនេះទឹកប្រាក់ដែលអាចប្រមូលបានមកវិញនៃទ្រព្យសកម្ម ត្រូវបានប៉ាន់ស្មានដើម្បីកំណត់ពីទំហំនៃការបាត់បង់លើការថយចុះនៃតម្លៃ (ប្រសិនបើមាន) ។ នៅពេលដែលមិនអាចប៉ាន់ស្មានបានពីចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញនៃទ្រព្យសកម្មបុគ្គល ក្រុមហ៊ុនធ្វើការប៉ាន់ស្មានថាចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្មនោះ។

ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញគឺតម្លៃខ្ពស់ជាងរវាងតម្លៃសមស្របដកនឹងថ្លៃដើមក្នុងការលក់ និងតម្លៃប្រើប្រាស់។ ក្នុងការវាយតម្លៃតម្លៃប្រើប្រាស់ លំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគតត្រូវបានធ្វើអប្បហារ ទៅតម្លៃបច្ចុប្បន្នរបស់ពួកគេដោយប្រើអត្រាអប្បហារមុនពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃតាមពេលវេលាហិរញ្ញវត្ថុ និងហានិភ័យជាក់លាក់ចំពោះទ្រព្យសកម្ម។

ប្រសិនបើទឹកប្រាក់ដែលអាចប្រមូលបានមកវិញនៃទ្រព្យសកម្ម (ឬអង្គភាពបង្កើតសាច់ប្រាក់) ត្រូវបានប៉ាន់ស្មានថាមានតម្លៃតិចជាងតម្លៃយោងរបស់ខ្លួននោះ តម្លៃយោងនៃទ្រព្យសកម្ម (អង្គភាពបង្កើតសាច់ប្រាក់) នឹងត្រូវបានកាត់បន្ថយមកត្រឹមទឹកប្រាក់ដែលអាចប្រមូលបានមកវិញ។ ការខាតបង់លើការថយចុះនៃតម្លៃត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត។

ក្នុងករណីដែលការខាតបង់លើការថយចុះនៃតម្លៃបញ្ច្រាសមកវិញ នោះតម្លៃយោងនៃទ្រព្យសកម្ម (អង្គភាពបង្កើតសាច់ប្រាក់) បានកើនឡើងទៅតាមការប៉ាន់ស្មានកែសម្រួលឡើងវិញនូវទឹកប្រាក់ដែលអាចប្រមូលបានមកវិញ ប៉ុន្តែតម្លៃយោងកើនឡើងមិនអាចលើសពីតម្លៃយោងដែលអាចត្រូវបានកំណត់ក្នុងករណីពុំមានការខាតបង់លើការថយចុះនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងទ្រព្យសកម្ម (អង្គភាពបង្កើតសាច់ប្រាក់) នៅឆ្នាំមុនៗ។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ង) ការថយចុះតម្លៃនៃទ្រព្យសកម្ម (ត)

**ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**

ការខាតបង់លើការថយចុះនៃតម្លៃទ្រព្យសកម្មដែលបានទទួលស្គាល់ពីមុន ក្រៅពីមូលនិធិពាណិជ្ជកម្ម (goodwill) នឹងត្រូវកត់ត្រាបញ្ច្រាសមកវិញ ប្រសិនបើមានការផ្លាស់ប្តូរការប៉ាន់ស្មានដើម្បីកំណត់ចំនួនតម្លៃដែលអាចប្រមូលបានមកវិញពីទ្រព្យសកម្ម ចាប់តាំងពីការបាត់បង់លើការថយចុះនៃតម្លៃត្រូវបានទទួលស្គាល់ជាចុងក្រោយ។ ការកត់ត្រាបញ្ច្រាសមកវិញនៃការថយចុះនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត។

### (ច) សន្និធិ

សន្និធិត្រូវបានយោងនៅតម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃពិតប្រាកដ។

ថ្លៃដើមត្រូវបានគណនាដោយប្រើវិធីសាស្ត្រមធ្យម ឬវិធីសាស្ត្រកំណត់ជាក់លាក់រួមមានរាល់ថ្លៃដើមនៃការទិញ ការចំណាយលើការបំលែង និងថ្លៃដើមផ្សេងទៀតដែលនាំយកសន្និធិទៅទីតាំង និងស្ថានភាពបច្ចុប្បន្នរបស់វា។

តម្លៃពិតប្រាកដ គឺជាតម្លៃលក់ប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតា ដកថ្លៃដើមប៉ាន់ស្មានសម្រាប់ធ្វើឲ្យរួចរាល់ និងថ្លៃដើមប៉ាន់ស្មានដែលចាំបាច់ដើម្បីលក់សន្និធិនោះ។

នៅពេលសន្និធិត្រូវបានលក់ តម្លៃយោងនៃសន្និធិទាំងនោះត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទ ខណៈពេលដែលប្រាក់ចំណូលពាក់ព័ន្ធក៏ត្រូវបានទទួលស្គាល់។ ទឹកប្រាក់សន្និធិលុបចេញពីបញ្ជីទៅតម្លៃពិតប្រាកដ និងការខាតបង់នៃសន្និធិទាំងអស់ត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទនៃការលុបចេញ ឬការខាតបង់កើតឡើង។ ទឹកប្រាក់នៃការកត់បញ្ច្រាសសន្និធិលុបចេញពីបញ្ជី ត្រូវបានទទួលស្គាល់ជាការកាត់បន្ថយទឹកប្រាក់សន្និធិ ដែលត្រូវបានទទួលស្គាល់ជាជាចំណាយក្នុងការិយបរិច្ឆេទដែលកំណត់បញ្ច្រាសបានកើតឡើង។

### (ឆ) គណនីត្រូវទទួល

គណនីត្រូវទទួល ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានសិទ្ធិគ្មានលក្ខខណ្ឌដើម្បីទទួលបានការទូទាត់សង។ សិទ្ធិដើម្បីទទួលបានការទូទាត់សងគ្មានលក្ខខណ្ឌ ប្រសិនបើការទូទាត់នោះដល់កំណត់ត្រូវសងបន្ទាប់ពីឆុតពេលវេលាដែលផ្តល់ឲ្យប៉ុណ្ណោះ។

គណនីត្រូវទទួលត្រូវបានកត់ត្រានៅថ្លៃដើមរំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ដកនឹងសំវិធានធនសម្រាប់ការបាត់បង់ឥណទាន។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ជ) កិច្ចសន្យាទ្រព្យសកម្ម /បំណុល

កិច្ចសន្យាទ្រព្យសកម្ម គឺជាសិទ្ធិក្នុងការទទួលបានសំណងសម្រាប់ការផ្ទេរទំនិញឬសេវាកម្មទៅឱ្យអតិថិជន នៅពេលដែលសិទ្ធិនោះមានលក្ខខណ្ឌលើអ្វីមួយជាជាងពេលវេលាដែលបានកន្លងផុតទៅ (ឧទាហរណ៍ការអនុវត្តនាពេលអនាគតរបស់ក្រុមហ៊ុន) ។

គោលនយោបាយសម្រាប់ទទួលស្គាល់ និងវាស់វែងលើការខាតបង់លើការថយចុះនៃតម្លៃគឺអនុលោមតាមកំណត់សំគាល់ទី ២ (ង) ។

កិច្ចសន្យាបំណុល គឺជាកាតព្វកិច្ចផ្ទេរទំនិញ ឬសេវាកម្មទៅឲ្យអតិថិជននៅពេលដែលក្រុមហ៊ុនបានទទួលការទូទាត់ ឬបានចេញវិក្កយបត្រជូនអតិថិជន។

### (ឈ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់នៅធនាគារ និងនៅក្នុងដៃ ការដាក់ប្រាក់ជាមួយធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ការវិនិយោគរយៈពេលខ្លី និងមានសន្ទនីយភាពខ្ពស់ ដែលអាចប្រឈមនឹងហានិភ័យតិចតួចនៃការផ្លាស់ប្តូរតម្លៃ មានរយៈពេលបីខែពីថ្ងៃចាប់ផ្តើម។

### (ញ) ប្រាក់កម្ចីមានការប្រាក់

ប្រាក់កម្ចីមានការប្រាក់ ត្រូវបានទទួលស្គាល់ដំបូងក្នុងតម្លៃសមស្របដកនឹងថ្លៃដើមប្រតិបត្តិការ។ បន្ទាប់ពីទទួលស្គាល់ ប្រាក់កម្ចីមានការប្រាក់ត្រូវបានកត់ត្រានៅថ្លៃដើមរំលស់ ភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានកត់ត្រាដំបូង និងតម្លៃរំលស់ត្រូវបានកត់ត្រាក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត ជាមួយនឹងការប្រាក់ ថ្លៃសេវាដែលត្រូវបង់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

### (ដ) គណនីត្រូវទូទាត់ផ្សេងៗ

គណនីត្រូវទូទាត់ផ្សេងៗត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃសមស្រប។ លើកលែងតែបំណុលជានាក់ព័ន្ធហិរញ្ញវត្ថុដែលបានវាស់វែងយោងតាមកំណត់សំគាល់ទី ២ (ឋ)(i)។ គណនីត្រូវទូទាត់ផ្សេងៗ ត្រូវបានកត់ត្រានៅថ្លៃដើមរំលស់ លើកលែងតែមានឥទ្ធិពលប៉ះពាល់នៃការបញ្ចុះថ្លៃដែលមិនមែនជាសារវន្ត ករណីនេះ ទើបវាត្រូវបានបង្ហាញនៅថ្លៃដើម។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ឋ) ការធានាហិរញ្ញវត្ថុដែលបានចេញផ្សាយ សំវិធានធន និងបំណុលជាយថាហេតុ

(i) ការធានាហិរញ្ញវត្ថុដែលបានបោះផ្សាយ

ការធានាហិរញ្ញវត្ថុគឺជាកិច្ចសន្យាដែលតម្រូវឱ្យអ្នកចេញផ្សាយ (ឧ. អ្នកធានា) ធ្វើការទូទាត់ជាក់ស្តែងសងទៅអ្នកទទួលផលពីការធានា (អ្នកកាន់កាប់) សម្រាប់ការខាតបង់ដែលអ្នកកាន់កាប់បានកើតឡើងដោយសារតែកូនបំណុលខកខានមិនបានទូទាត់ប្រាក់ ដោយយោងទៅតាមលក្ខខណ្ឌនៃលិខិតឧបករណ៍បំណុល។

នៅពេលដែលក្រុមហ៊ុនចេញផ្សាយការធានាហិរញ្ញវត្ថុ តម្លៃសមស្របនៃការធានា (គឺជាថ្លៃប្រតិបត្តិការលើកលែងតែតម្លៃសមស្របអាចធ្វើការប៉ាន់ស្មានដោយទុកចិត្តបាន) ត្រូវបានទទួលស្គាល់ដំបូងថាជាប្រាក់ចំណូលពន្យារនៅក្នុងគណនីត្រូវទូទាត់ផ្សេងៗទៀត។ នៅពេលដែលតម្លៃតបស្នងត្រូវបានទទួល ឬអាចទទួលបានពីការចេញលិខិតធានា តម្លៃតបស្នងត្រូវបានទទួលស្គាល់អនុលោមតាមគោលការណ៍របស់ក្រុមហ៊ុន ដែលត្រូវអនុវត្តចំពោះប្រភេទនៃទ្រព្យសកម្មនោះ។ នៅពេលដែលគ្មានតម្លៃតបស្នងបានទទួល ឬនឹងត្រូវបានទទួល ការចំណាយណាមួយត្រូវទទួលស្គាល់ក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាតលើការទទួលស្គាល់ដំបូងនៃប្រាក់ចំណូលពន្យារ។

ចំនួនទឹកប្រាក់នៃការធានាត្រូវបានទទួលស្គាល់ដំបូងជាប្រាក់ចំណូលពន្យារ ត្រូវបានរំលស់នៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត ក្នុងរយៈពេលនៃការធានាដែលជាប្រាក់ចំណូលពីការធានាហិរញ្ញវត្ថុដែលបានចេញផ្សាយ។ លើសពីនេះទៀតសំវិធានធនត្រូវបានទទួលស្គាល់ស្របតាមកំណត់សំគាល់ ២ (ឋ) (ii) ប្រសិនបើនិងនៅពេល (i) អ្នកកាន់កាប់ការធានាទាមទារដល់ក្រុមហ៊ុនក្រោមការធានានិង (ii) ចំនួនទឹកប្រាក់នៃការទាមទារសំណងនោះ ត្រូវបានគេរំពឹងថានឹងមានចំនួនលើសពីចំនួនទឹកប្រាក់ដែលត្រូវបានកត់ត្រាក្នុងបញ្ជីគណនីត្រូវទូទាត់ផ្សេងៗ ដែលទាក់ទងនឹងការធានានេះ ឧ. ទឹកប្រាក់ទទួលស្គាល់ដំបូងដកំរំលស់បង្គរ។

(ii) សំវិធានធនផ្សេងៗ និងបំណុលជាយថាហេតុ

សំវិធានធនត្រូវបានទទួលស្គាល់ជាគណនីត្រូវទូទាត់ផ្សេងៗ ដែលមានពេលវេលា ឬចំនួនទឹកប្រាក់មានភាពមិនច្បាស់លាស់ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់ ឬ constructive ដែលកើតឡើងដោយសារព្រឹត្តិការណ៍កន្លងមក លំហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងអាចកើតឡើងដែលតម្រូវឲ្យមានការទាមទារដោះស្រាយកាតព្វកិច្ច និងការប៉ាន់ស្មានដែលអាចទុកចិត្តត្រូវបានធ្វើ ឡើង។ នៅពេលដែលតម្លៃពេលវេលាហិរញ្ញវត្ថុជាសារវន្ត សំវិធានធនត្រូវបានកត់ត្រានៅតម្លៃបច្ចុប្បន្នចំពោះការចំណាយដែលរំពឹងថានឹងត្រូវទូទាត់កាតព្វកិច្ចនេះ។

ក្នុងករណីដែលលំហូរចេញផលប្រយោជន៍សេដ្ឋកិច្ចដែលត្រូវទាមទារ ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបានមិនអាចកើតឡើងទេ នោះកាតព្វកិច្ចនេះត្រូវបង្ហាញជាបំណុលជាយថាហេតុលើកលែងតែប្រូបាបនៃលំហូរផលប្រយោជន៍សេដ្ឋកិច្ចគឺមានចំនួនតិចតួច។ កាតព្វកិច្ចដែលអាចកើតឡើងឬមិនកើតឡើងនៃព្រឹត្តិការណ៍មួយ ឬច្រើននាពេលអនាគតត្រូវបានបង្ហាញជាបំណុលជាយថាហេតុដែលលើកលែងតែប្រូបាបនៃលំហូរផលប្រយោជន៍សេដ្ឋកិច្ចមានចំនួនតិចតួច។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ឌ) ដើមទុន

ភាគហ៊ុនធម្មតាគឺជាឧបករណ៍មូលបត្រកម្មសិទ្ធិ។ ឧបករណ៍មូលបត្រកម្មសិទ្ធិ គឺជាកិច្ចសន្យាមួយដែលបង្ហាញពីភស្តុតាងតម្លៃសេសសល់លើទ្រព្យសកម្មរបស់ក្រុមហ៊ុនបន្ទាប់ពីកាត់កងបំណុលទាំងអស់។ ភាគហ៊ុនត្រូវបានគេកត់ត្រាពេលដែលទទួលបានមូលធន ដោយដកចំណាយបន្ថែមចេញពីមូលធន។ ភាគលាភលើភាគហ៊ុនធម្មតាត្រូវបានទទួលស្គាល់នៅក្នុងមូលធនក្នុងរយៈពេលដែលត្រូវបានប្រកាស។

### (ឍ) ការទទួលស្គាល់ចំណូល និងចំណូលផ្សេងៗ

ប្រាក់ចំណូល ត្រូវបានទទួលស្គាល់នៅពេលដែលការគ្រប់គ្រងលើផលិតផល ឬសេវាកម្មត្រូវបានផ្ទេរទៅឱ្យអតិថិជនតាមចំនួនទឹកប្រាក់ដែលបានសន្យា នៅពេលដែលក្រុមហ៊ុនត្រូវបានគេរំពឹងថានឹងមានសិទ្ធិ ដោយមិនរាប់បញ្ចូលចំនួនទឹកប្រាក់ដែលប្រមូលបានសម្រាប់ភាគីទីបី។ ព័ត៌មានលំអិតបន្ថែមទៀតអំពីប្រាក់ចំណូលរបស់ក្រុមហ៊ុន និងគោលនយោបាយទទួលស្គាល់មានដូចខាងក្រោម៖

(i) ប្រាក់ចំណូលពីការលក់ទំនិញ ឬសេវាកម្ម ត្រូវបានទទួលស្គាល់នៅពេលដែលទំនិញបានប្រគល់ឬសិទ្ធិនៃការគ្រប់គ្រងបានផ្ទេរឲ្យទៅអតិថិជន

(ii) ចំណូលការប្រាក់ត្រូវបានទទួលស្គាល់តាមពេលវេលា ដែលបានបង្ករដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

### (ណ) អត្ថប្រយោជន៍បុគ្គលិក

ប្រាក់ខែ ប្រាក់រង្វាន់បំណាច់ឆ្នាំ ការឈប់សម្រាកប្រចាំឆ្នាំ ការរួមចំណែកដល់ផែនការចូលនិវត្តន៍ដែលបានកំណត់ និងថ្លៃដើមនៃអត្ថប្រយោជន៍មិនមែនរូបិយវត្ថុដែលបានបង្គរក្នុងឆ្នាំនៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ជូនដោយនិយោជិក។ នៅពេលដែលមានការទូទាត់ ឬការទូទាត់ត្រូវបានពន្យារ ហើយផលប៉ះពាល់នឹងក្លាយជាសារវន្ត ទឹកប្រាក់ទាំងនេះនឹងត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ន។

### (ត) ប្រាក់កម្ចី

ចំណាយលើប្រាក់កម្ចីគឺជាចំណាយក្នុងរយៈពេលដែលបានកើតឡើង លើកលែងតែទំហំដែលត្រូវទទួលស្គាល់ជាទ្រព្យ ដែលកើតឡើងដោយផ្ទាល់ទៅនឹងការទិញយក ការសាងសង់ ឬការផលិតទ្រព្យសកម្មដែលចាំបាច់ត្រូវការរយៈពេលច្រើនដើម្បីត្រៀមរួចរាល់សម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក ឬការលក់។

### (ថ) ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណេញ ឬខាតសម្រាប់ឆ្នាំរួមមានពន្ធបច្ចុប្បន្ន និងពន្ធពន្យារ។ ពន្ធបច្ចុប្បន្ន និងពន្ធពន្យារត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត លើកលែងតែទំនិញដែលត្រូវទទួលស្គាល់នៅខាងក្រៅរបាយការណ៍ប្រាក់ចំណេញ ឬខាត ទាំងនៅក្នុងប្រាក់ចំណូលលម្អិតផ្សេងៗឬដោយផ្ទាល់ក្នុងមូលធនដែលពន្ធនេះត្រូវបានទទួលស្គាល់ក្រៅរបាយការណ៍ប្រាក់ចំណេញ ឬខាត (ទាំងនៅក្នុងប្រាក់ចំណូលលម្អិតផ្សេងៗ ឬដោយផ្ទាល់នៅក្នុងមូលធនរៀងគ្នា)។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ថ) ពន្ធលើប្រាក់ចំណូល (ត)

ពន្ធបច្ចុប្បន្ន គឺជាបំណុលពន្ធរំពឹងទុក ឬអាចប្រមូលបានមកវិញលើប្រាក់ចំណូលដែលជាប់ពន្ធសម្រាប់ឆ្នាំបច្ចុប្បន្ន ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬត្រូវបានអនុម័តនៅចុងបញ្ចប់នៃការិយបរិច្ឆេទរបាយការណ៍ និងការកែសម្រួលពន្ធដែលត្រូវបង់ ឬអាចប្រមូលមកវិញបានទាក់ទងនឹងឆ្នាំមុនៗ។

ពន្ធពន្យារលើប្រាក់ចំណូល ត្រូវបានផ្តល់ដោយប្រើវិធីសាស្ត្របំណុលលើភាពខុសគ្នាបណ្តោះអាសន្នទាំងអស់នៅចុងបញ្ចប់ការិយបរិច្ឆេទ ដែលកើតឡើងរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងនៅរបាយការណ៍ហិរញ្ញវត្ថុ លើកលែងតែពន្ធពន្យារលើប្រាក់ចំណូលពីការទទួលស្គាល់ដំបូងនៃមូលនិធិពាណិជ្ជកម្ម (goodwill) ឬទ្រព្យសកម្ម ឬបំណុលនៅក្នុងប្រតិបត្តិការដែលមិនមែនជាការរួមបញ្ចូលអាជីវកម្ម ហើយនៅពេលប្រតិបត្តិការមិនប៉ះពាល់ដល់គណនេយ្យ និងប្រាក់ចំណេញ ឬខាតបង់ឡើយ។

ពន្ធពន្យារទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ក្នុងករណីដែលអាចនឹងទទួលបានប្រាក់ចំណេញជាប់ពន្ធដែលអាចដកប្រើប្រាស់បាន។

ពន្ធពន្យារទ្រព្យសកម្ម និងបំណុលត្រូវបានវាស់តាមអត្រាពន្ធដែលរំពឹងថានឹងអនុវត្តក្នុងឆ្នាំ នៅពេលដែលទ្រព្យសកម្មត្រូវបានទទួលស្គាល់ ឬបំណុលបានទូទាត់ដោយផ្អែកលើអត្រាពន្ធដែលបានអនុម័តនៅចុងការិយបរិច្ឆេទ។

### (ទ) ការបកប្រែរូបិយប័ណ្ណបរទេស

ប្រតិបត្តិការរូបិយប័ណ្ណបរទេសនៅក្នុងការិយបរិច្ឆេទ ត្រូវបានប្តូរទៅអត្រាប្តូរប្រាក់បរទេសនៅថ្ងៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុដែលគិតជារូបិយប័ណ្ណបរទេសត្រូវបានប្តូរទៅអត្រាប្តូរប្រាក់បរទេសនៅចុងការិយបរិច្ឆេទនីមួយៗ។ ប្រាក់ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត។

ទ្រព្យសកម្ម និងបំណុលមិនមែនជារូបិយវត្ថុ ត្រូវបានវាស់វែងនៅថ្លៃដើមប្រវត្តិសាស្ត្រក្នុងរូបិយប័ណ្ណបរទេសត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់បរទេសនៅថ្ងៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលមិនមែនជារូបិយវត្ថុដែលគិតជារូបិយប័ណ្ណបរទេសដែលបានកត់ត្រានៅតម្លៃសមស្រប ត្រូវបានប្តូរទៅអត្រាប្តូរប្រាក់បរទេសតាមកាលបរិច្ឆេទដែលតម្លៃសមស្របបានកំណត់។

### (ធ) ភាគីពាក់ព័ន្ធ

(ក) បុគ្គលម្នាក់ ឬសមាជិកជិតស្និទ្ធនៃគ្រួសាររបស់បុគ្គលនោះ មានទំនាក់ទំនងជាមួយក្រុមហ៊ុន ប្រសិនបើបុគ្គលនោះ៖

(i) មានការគ្រប់គ្រង ឬគ្រប់គ្រងរួមលើក្រុមហ៊ុន។

(ii) មានឥទ្ធិពលគួរឱ្យកត់សម្គាល់លើក្រុមហ៊ុន។ ឬ

(iii) គឺជាសមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់របស់ក្រុមហ៊ុន ឬក្រុមហ៊ុនកាន់កាប់ផ្ទាល់របស់ក្រុមហ៊ុន។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ( ត )

### (ផ) ភាគីពាក់ព័ន្ធ (ត)

(ខ) អង្គភាពមានជាប់ទាក់ទងនឹងក្រុមហ៊ុន ប្រសិនបើមានលក្ខខណ្ឌណាមួយដូចខាងក្រោម៖

(i) អង្គភាព និងក្រុមហ៊ុនគឺជាសមាជិកនៃក្រុមតែមួយ (ដែលមានន័យថាក្រុមហ៊ុនកាន់កាប់ផ្ទាល់នីមួយៗ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងទៀតដែលមានទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនដទៃផ្សេងទៀត)

(ii) អង្គភាពមួយ គឺជាការចូលរួមឬការបណ្តាក់ទុនរួមគ្នារបស់អង្គភាពផ្សេងទៀត (ឬសមាគម ឬក្រុមហ៊ុនរួមទុនរបស់សមាជិកនៃក្រុមអង្គភាពផ្សេងទៀតគឺជាសមាជិក)

(iii) អង្គភាពទាំងពីរគឺជាក្រុមហ៊ុនរួមទុនរបស់ភាគីទីបីដូចគ្នា

(iv) នីតិបុគ្គលមួយ គឺជាក្រុមហ៊ុនរួមទុននៃអង្គភាពទីបី ហើយអង្គភាពផ្សេងទៀតគឺជាអង្គភាពនៃអង្គភាពទីបី

(v) អង្គភាពគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយបុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុង (ក)

(vi) បុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុង (ក) (i) មានឥទ្ធិពលគួរឱ្យកត់សម្គាល់លើអង្គភាពឬជាសមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់នៃអង្គភាព (ឬឪពុកម្តាយរបស់អង្គភាព)

(vii) អង្គភាព ឬសមាជិកនៃក្រុមណាមួយដែលជាផ្នែកមួយផ្តល់នូវសេវាកម្មបុគ្គលិកគ្រប់គ្រងសំខាន់ៗដល់ក្រុមហ៊ុន ឬដល់ក្រុមហ៊ុនដែលកាន់កាប់ផ្ទាល់របស់ក្រុមហ៊ុន។

សមាជិកជិតស្និទ្ធនៃក្រុមគ្រួសាររបស់មនុស្សម្នាក់ គឺជាសមាជិកគ្រួសារទាំងនោះដែលអាចត្រូវបានគេរំពឹងថានឹងមានឥទ្ធិពល ឬទទួលឥទ្ធិពលពីបុគ្គលនោះក្នុងការទំនាក់ទំនងជាមួយអង្គភាព។

### (ន) ប្រតិបត្តិការតាមផ្នែក

ប្រតិបត្តិការតាមផ្នែកត្រូវបានរាយការណ៍តាមរបៀបដែលស្របទៅនឹងរបាយការណ៍ផ្ទៃក្នុង ដែលបានផ្តល់ជូនដល់ប្រធានប្រតិបត្តិការ ដែលជាអ្នកធ្វើការសំរេចចិត្ត។ នាយកប្រតិបត្តិរបស់ក្រុមហ៊ុនដែលទទួលខុសត្រូវក្នុងការបែងចែកធនធាន និងវាយតម្លៃការអនុវត្តន៍នៃប្រតិបត្តិការតាមផ្នែក ត្រូវបានគេកំណត់ថាជាប្រធានប្រតិបត្តិការ ដែលជាអ្នកធ្វើការសំរេចចិត្តលើយុទ្ធសាស្ត្រ។

### (យ) ឧបករណ៍ហិរញ្ញវត្ថុ

#### (ក) ចំណាត់ថ្នាក់ និងការវាស់វែងនៃឧបករណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុនបានចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុជាបីចំណាត់ថ្នាក់ចម្បង៖ វាស់វែងដោយថ្លៃដើមរំលស់ នៅតម្លៃសមស្របតាមរយៈប្រាក់ចំណូលលម្អិតផ្សេងៗ និងតាមតម្លៃសមស្របនៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត ។ ចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុគឺពឹងផ្អែកលើគំរូអាជីវកម្មដែលគ្រប់គ្រងដោយទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខណៈលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

ក្រុមហ៊ុន មិនបានកំណត់បំណុលហិរញ្ញវត្ថុណាមួយនៅតម្លៃសមស្របតាមរយៈរបាយការណ៍ចំណេញ ឬខាតឡើយ។ មិនមានការផ្លាស់ប្តូរចំណាត់ថ្នាក់ និងការវាស់វែងសម្រាប់បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

### (ឃ) ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### (ខ) ការបង់បាត់ឥណទាន

គំរូការបាត់បង់ឥណទានរំពឹងទុក តម្រូវឱ្យមានការវាស់វែងបន្តនៃហានិភ័យឥណទានដែលទាក់ ទង នឹងទ្រព្យសកម្មហិរញ្ញវត្ថុ ដូច្នេះត្រូវទទួលស្គាល់ការបាត់បង់ឥណទានរំពឹងទុកមុនការទទួលស្គាល់ "ការបាត់បង់" ដែលធ្វើក្រោមគំរូគណនេយ្យ ។

ក្រុមហ៊ុនអនុវត្តគំរូការបាត់បង់ឥណទានរំពឹងទុកថ្មី ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុណាដែលត្រូវបាន វាស់វែងនៅថ្លៃដើមរំលស់ (រួមបញ្ចូលទាំងគណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ ទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធ និងសាច់ប្រាក់ និងសាច់ប្រាក់សមមូល)។

### (ង) ការវាស់វែងតម្លៃសមស្រប

ការវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល លើកលែងតែការទូទាត់ផ្អែកលើភាគហ៊ុនត្រូវបានកំណត់ជាថ្លៃដែលត្រូវទទួលបាននៅពេលលក់ទ្រព្យសកម្ម ឬទូទាត់នៅពេលផ្ទេរបំណុល ក្នុងប្រតិបត្តិការធម្មតារវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទវាស់វែង។ ការវាស់វែងត្រូវបានសន្មតថាជាប្រតិបត្តិការលក់ទ្រព្យសកម្ម ឬទូទាត់ នៅពេលផ្ទេរបំណុល កើតឡើងទាំងក្នុងទីផ្សារគោល ឬអវត្តមានទីផ្សារគោល។

សម្រាប់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ការវាស់វែងតម្លៃសមស្របត្រូវគិតពីលទ្ធភាពអ្នកចូលរួមក្នុងទីផ្សារ ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចដោយប្រើប្រាស់ទ្រព្យសកម្មក្នុងតម្លៃខ្ពស់បំផុត និងការប្រើប្រាស់ល្អបំផុត ឬដោយការលក់ទៅឱ្យអ្នកចូលរួមទីផ្សារផ្សេងទៀតដែលអាចប្រើប្រាស់ទ្រព្យសកម្មក្នុងតម្លៃខ្ពស់បំផុត និងការប្រើប្រាស់ល្អបំផុត។

នៅពេលវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល ក្រុមហ៊ុនត្រូវប្រើទិន្នន័យអង្កេតទីផ្សារដែលមាន។ តម្លៃសមស្របត្រូវបានចាត់ថ្នាក់ទៅតាមកម្រិតខុសគ្នាតាមឋានានុក្រមតម្លៃសមស្របដោយផ្អែកលើការប្រើប្រាស់បច្ចេកទេសវាយតម្លៃដូចខាងក្រោម៖

កម្រិត ១ : ការស្រង់ថ្លៃ (មិនបានកែតម្រូវ) ក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុល ដូចគ្នា ដែលក្រុមហ៊ុន និងក្រុមហ៊ុន អាចទទួលបាននៅកាលបរិច្ឆេទវាយតម្លៃ។
កម្រិត ២ : ធាតុចូលជាជាងការស្រង់ថ្លៃមានក្នុងកម្រិត ១ ដែលត្រូវបានអង្កេតសម្រាប់ ទ្រព្យសកម្ម ឬបំណុល ទាំងផ្ទាល់ ឬមិនផ្ទាល់។
កម្រិត ៣ : ធាតុចូលមិនអាចអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាងកម្រិតតាមឋានានុក្រមតម្លៃសមស្រប ជាកាលបរិច្ឆេទនៃព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរស្ថានភាព ដែលបណ្តាលឱ្យមានការផ្ទេរ។

## ៣. ការអនុលោមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងការធ្វើវិសោធនកម្ម ឬកំណែលំអរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

### (ក) វិសោធនកម្ម ឬកំណែលំអរទៅជាស្តង់ដារដែលអនុលោមដោយក្រុមហ៊ុន

ក្រុមហ៊ុនបានអនុវត្តស្តង់ដារ ធ្វើវិសោធនកម្ម ឬកំណែលម្អទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្នដូចខាងក្រោម៖

<u>វិសោធនកម្ម ឬកំណែលំអរទៅជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា</u>

- ការរួមបញ្ចូលអាជីវកម្ម (CIFRS ៣)
- ឧបករណ៍ហិរញ្ញវត្ថុ៖ ការបង្ហាញ (CIFRS ៧)
- ឧបករណ៍ហិរញ្ញវត្ថុ (CIFRS ៩)
- ភតិសន្យា (CIFRS ១៦)
- បទបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុ (CIAS ១)
- គោលនយោបាយគណនេយ្យ បម្រែបម្រួលនៃការសន្មតគណនេយ្យ និងកំហុសឆ្គង (CIAS ៨)
- ឧបករណ៍ហិរញ្ញវត្ថុ៖ ការទទួលស្គាល់ និងការវាស់វែង (CIAS ៣៩)

ការអនុលោមលើស្តង់ដារគណនេយ្យ ការធ្វើវិសោធនកម្ម និងបំណកស្រាយខាងលើ មិនមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### (ខ) ស្តង់ដារថ្មី និងការធ្វើវិសោធនកម្ម ឬកំណែលំអរដែលមិនទាន់អនុលោម

ស្តង់ដារគណនេយ្យ និងការធ្វើវិសោធនកម្មមួយចំនួនត្រូវបានបោះពុម្ពផ្សាយដែលមិនទាន់ចាំបាច់សម្រាប់ការិយបរិច្ឆេទរាយការណ៍ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ មិនទាន់ត្រូវបានអនុលោមដោយក្រុមហ៊ុនជាមុនទេ។ ស្តង់ដារទាំងនេះ មិនត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តទៅលើការិយបរិច្ឆេទរាយការណ៍របស់ក្រុមហ៊ុននាពេលបច្ចុប្បន្ន ឬការិយបរិច្ឆេទរាយការណ៍នាពេលអនាគត និងលើប្រតិបត្តិការនាពេលអនាគតដែលអាចមើលឃើញជាមុននោះទេ។

## ៤. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ផ្នែកសំខាន់ៗនៃការប៉ាន់ស្មាន ភាពមិនច្បាស់លាស់ និងការវិនិច្ឆ័យសំខាន់ៗ ដើម្បីអនុវត្តតាមគោលនយោបាយគណនេយ្យ ដែលមានផលប៉ះពាល់សំខាន់ៗក្នុងការកំណត់តម្លៃបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

### (ក) រំលស់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ និងបរិក្ខារ

ដូចមានបង្ហាញក្នុងកំណត់សម្គាល់ ២ (ឥ) ក្រុមហ៊ុនបានពិនិត្យតម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់នៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ។ ការប៉ាន់ស្មាន ត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសវិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់។ ការប្រើប្រាស់ជាក់ស្តែងនៃអត្ថប្រយោជន៍របស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ អាចខុសគ្នាពីការប៉ាន់ស្មាន ដូចនេះការរំលស់នាពេលអនាគតអាចនឹងត្រូវពិនិត្យឡើងវិញ។

តម្លៃយោងរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខាររបស់ក្រុមហ៊ុន ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ១០។

**អេ អឹម អេ (ខេមបូឌា) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ៤. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### (ខ) ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ក្រុមហ៊ុនវាយតម្លៃការថយចុះនៃតម្លៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ រាល់ពេលដែលព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈដែលចង្អុលបង្ហាញថាតម្លៃយោងនៃទ្រព្យសកម្មអាចនឹងមិនទទួលបានមកវិញ ឧទាហរណ៍ តម្លៃយោងនៃទ្រព្យសកម្មច្រើនជាងតម្លៃដែលអាចទទួលបានមកវិញ។

តម្លៃដែលអាចទទួលបានមកវិញ ត្រូវបានវាស់នៅតម្លៃខ្ពស់ជាងតម្លៃសមស្របដកចំណាយការលក់សម្រាប់ទ្រព្យសកម្ម និងតម្លៃក្នុងការប្រើប្រាស់។ តម្លៃក្នុងការប្រើប្រាស់ គឺតម្លៃបច្ចុប្បន្នសុទ្ធនៃលំហូរសាច់ប្រាក់នាពេលអនាគតដែលត្រូវបានរំពឹងថានឹងទទួលបានពីទ្រព្យសកម្មនោះ ដោយធ្វើអប្បហារនៅអត្រាការប្រាក់អប្បហារសមស្រប។ ក្រុមហ៊ុនប្រើការវិនិច្ឆ័យដើម្បីកំណត់អត្រាអប្បហារក្នុងការគណនាតម្លៃដែលអាចទទួលបានមកវិញនិងការសន្មតការព្យាករណ៍លំហូរសាច់ប្រាក់ រួមទាំងអត្រាកំណើនព្យាករណ៍ អត្រាអតិផរណា និងប្រាក់ចំណេញដុល។

លំហូរសាច់ប្រាក់ព្យាករណ៍ផ្អែកលើធាតុចូល ឬការសន្មត ដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ប្រសិនបើលំហូរសាច់ប្រាក់ជាក់ស្តែងតិចជាងការរំពឹងទុក។

តម្លៃយោងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ១០ ១១ និង ១៣ ។

### (គ) ការលុបចោលសន្និធិដែលហួសសម័យ ឬសន្និធិដែលធ្វើចលនាយឺត

ក្រុមហ៊ុនលុបចោលសន្និធិដែលហួសសម័យ ឬសន្និធិដែលធ្វើចលនាយឺត ដោយផ្អែកលើការវាយតម្លៃនៃការប៉ាន់ស្មានថ្លៃលក់ពិតរបស់សន្និធិនោះ។ សន្និធិដែលត្រូវបានលុបចោលនៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរក្នុងស្ថានភាពដែលចង្អុលបង្ហាញថា តម្លៃយោងនឹងមិនអាចទទួលបានមកវិញ។ គណៈគ្រប់គ្រងវិភាគនិន្នាការលក់ និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន នៅពេលធ្វើការវិនិច្ឆ័យដើម្បីវាយតម្លៃការលុបចោលសន្និធិដែលហួសសម័យ ឬសន្និធិដែលធ្វើចលនាយឺត។ នៅពេលដែលការរំពឹងទុកខុសពីការប៉ាន់ស្មានដំបូង ភាពខុសគ្នានោះ នឹងប៉ះពាល់ដល់តម្លៃយោងរបស់សន្និធិ។

តម្លៃយោងសន្និធិរបស់ក្រុមហ៊ុនត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ១៤។

### (ឃ) ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មកិច្ចសន្យា

សំវិធានធននៃការធ្លាក់ចុះនៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មកិច្ចសន្យាត្រូវពឹងផ្អែកលើការសន្មតអំពីហានិភ័យអត្រាការប្រាក់ និងការខាតបង់អត្រាការប្រាក់រំពឹងទុក។ ក្រុមហ៊ុនប្រើការវិនិច្ឆ័យដើម្បីធ្វើការសន្មត់ទាំងនេះ និងការជ្រើសរើសធាតុចូលទៅគណនាការថយចុះនៃតម្លៃដោយផ្អែកលើប្រវត្តិក្រុមហ៊ុនកាលពីមុន លក្ខខណ្ឌស្ថានភាពទីផ្សារដែលមានស្រាប់ ក៏ដូចជាការប៉ាន់ស្មានទៅមុខនៅចុងបញ្ចប់ការិយបរិច្ឆេទរាយការណ៍នីមួយៗ។

## ៤. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### (ឃ) ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មកិច្ចសន្យា (ត)

ក្រុមហ៊ុនប្រើម៉ាទ្រីសសំវិធានធន ដើម្បីគណនាការបាត់បង់ឥណទានរំពឹងទុកសម្រាប់គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ និងទ្រព្យសកម្មកិច្ចសន្យា។ អត្រាការប្រាក់គឺអាស្រ័យលើចំនួនថ្ងៃដែលគណនីអតិថិជនពាណិជ្ជកម្មទទួលបានហួសកំណត់។ ក្រុមហ៊ុនធ្វើការចែកជាក្រុមចំពោះអតិថិជនដែលមានលំនាំបាត់បង់ស្រដៀងគ្នា។ លក្ខណៈវិនិច្ឆ័យរួមមានតំបន់ភូមិសាស្ត្រ ប្រភេទផលិតផល ប្រភេទអតិថិជន និងចំណាត់ថ្នាក់ទ្រព្យបញ្ចាំ ឬការធានារ៉ាប់រងឥណទានពាណិជ្ជកម្ម។

ម៉ាទ្រីសនៃការផ្តល់ត្រូវបានផ្អែកដំបូងតាមការសង្កេតឃើញជាប្រវត្តិសាស្ត្ររបស់ក្រុមហ៊ុន។ ក្រុមហ៊ុននឹងក្រិតតាមខ្នាតម៉ាទ្រីសដើម្បីកែសម្រួលបទពិសោធប្រវត្តិសាស្ត្រនៃការបាត់បង់ឥណទាន ជាមួយនឹងព័ត៌មានឆ្ពោះទៅមុខ។ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ អត្រាការប្រាក់ដែលបានសង្កេតឃើញជាប្រវត្តិសាស្ត្រត្រូវបានធ្វើបច្ចុប្បន្នភាព ហើយការផ្លាស់ប្តូរការប៉ាន់ស្មានសម្លឹងទៅមុខត្រូវបានវិភាគ។

ការវាយតំលៃការជាប់ទាក់ទងគ្នារវាងអត្រាមិនប្រក្រតីនៃប្រវត្តិសាស្ត្រ ការប៉ាន់ស្មានទៅមុខ និងការបាត់បង់ឥណទានដែលរំពឹងទុកគឺជាការប៉ាន់ស្មានដ៏សំខាន់មួយ។ ចំនួនទឹកប្រាក់នៃការបាត់បង់ឥណទានរំពឹងទុកគឺមានភាពរសើបចំពោះការផ្លាស់ប្តូរកាលៈទេសៈ និងការព្យាករណ៍លក្ខខណ្ឌសេដ្ឋកិច្ចលើអាយុកាលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មកិច្ចសន្យា។ បទពិសោធន៍ការបាត់បង់ឥណទានជាប្រវត្តិសាស្ត្ររបស់ក្រុមហ៊ុន និងការព្យាករណ៍អំពីស្ថានភាពសេដ្ឋកិច្ចក៏អាចមិនតំណាងឱ្យភាពមិនពិតប្រាកដរបស់អតិថិជននាពេលអនាគតនោះទេ។

ព័ត៌មានអំពីការខាតបង់លើការថយចុះនៃតម្លៃទ្រព្យសកម្ម និងទ្រព្យសកម្មកិច្ចសន្យារបស់ក្រុមហ៊ុនត្រូវបានបង្ហាញនៅកំណត់សម្គាល់ ១៥ (ខ)។

### (ង) សំវិធានធន

ក្រុមហ៊ុនបានប្រើប្រាស់ "ការប៉ាន់ស្មានល្អបំផុត" ជាមូលដ្ឋានសម្រាប់កត់សំវិធានធន។ គណៈគ្រប់គ្រងបានវាយតម្លៃការប៉ាន់ស្មានដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្ររបស់ក្រុមហ៊ុន និងការបញ្ចូល ឬការសន្មតផ្សេងទៀត ការវិវឌ្ឍន៍បច្ចុប្បន្ន និងព្រឹត្តិការណ៍នាពេលអនាគតដែលអាចធ្វើទៅបានក្រោមហេតុផលជាក់លាក់។ ក្នុងករណីដែលសំវិធានធនទាក់ទងនឹងអតិថិជនច្រើន (ដូចជាសំវិធានធនធានាលើការធានា) ការប៉ាន់ប្រមាណផលប៉ះពាល់នៃលំហូរចេញដែលត្រូវការដើម្បីដោះស្រាយកាតព្វកិច្ចត្រូវបានប្រើ។ ក្នុងករណីការប៉ាន់ស្មានតែមួយ (ដូចជាសំវិធានធនសម្រាប់ថ្លៃដើមនៃការដ្ឋាន) តម្លៃរបស់អ្នកចុះកិច្ចសន្យាយោង ឬតម្លៃទីផ្សារត្រូវបានប្រើជាការប៉ាន់ស្មានដ៏ល្អបំផុត។ ប្រសិនបើកាតព្វកិច្ចត្រូវដោះស្រាយតាមពេលវេលាលំហូរចេញរំពឹងទុកនឹងត្រូវធ្វើអប្បហារទៅតាមអត្រា ដែលគិតពីតម្លៃពេលវេលានៃប្រាក់និងហានិភ័យដែលលទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានដែលបានធ្វើ។

តម្លៃយោងសំវិធានធនរបស់ក្រុមហ៊ុនត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ២០។

## ៤. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### (ខ) រង្វាស់ពន្ធលើប្រាក់ចំណូល

ការវិនិច្ឆ័យសំខាន់គឺចាំបាច់ក្នុងការកំណត់ការប៉ាន់ប្រមាណរបស់ក្រុមហ៊ុនចំពោះពន្ធក្នុងគ្រា និងពន្ធពន្យារ ព្រោះបំណុលពន្ធចុងក្រោយរបស់ក្រុមហ៊ុនទាំងមូលមិនមានភាពច្បាស់លាស់។ នៅពេលលទ្ធផលចុងក្រោយនៃប្រាក់ពន្ធដែលត្រូវបង់ ត្រូវបានកំណត់ដោយអាជ្ញាធរពន្ធដារក្នុងយុត្តាធិការនីមួយៗ ទឹកប្រាក់បង់ពន្ធនេះអាចខុសគ្នាពីការប៉ាន់ស្មានដំបូងនៃប្រាក់ពន្ធដែលត្រូវបង់។ ភាពខុសគ្នានេះអាចប៉ះពាល់ដល់ពន្ធក្នុងគ្រា និងពន្ធពន្យារ ក្នុងគ្រាដែលបានកំណត់។ ក្រុមហ៊ុននឹងធ្វើនិយ័តកម្មពន្ធក្នុងគ្រា ឬពន្ធពន្យារពីឆ្នាំមុនក្នុងគ្រាបច្ចុប្បន្នលើភាពខុសគ្នាទាំងនោះ។

ចំណាយពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុនត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៨ ។

### (គ) បំណុលជាយថាហេតុ

ក្រុមហ៊ុនអនុវត្តការវិនិច្ឆ័យក្នុងការវាស់វែង និងការទទួលស្គាល់សំវិធានធន និងការប្រឈមការប៉ះពាល់ទៅនឹងបំណុលជាយថាហេតុដែលជាប់ទាក់ទងនឹងវិវាទដែលមិនទាន់សម្រេច ឬការទាមទារសំណងផ្សេងទៀតដែលស្ថិតក្រោមការចរចារដោះស្រាយវិវាទអាជ្ញាកណ្តាល ឬបទប្បញ្ញត្តិរបស់រដ្ឋាភិបាល។ ការវិនិច្ឆ័យត្រូវបានទាមទារដើម្បីវាយតម្លៃលទ្ធភាពដែលការទាមទារដែលមិនទាន់សម្រេចនឹងទទួលបានជោគជ័យ ឬបំណុលនឹងកើតឡើងហើយកំណត់បរិមាណ ដែលអាចកើតមាននៃដំណោះស្រាយហិរញ្ញវត្ថុណាមួយ។ ភាពមិនប្រាកដប្រជានៃបញ្ហាបែបនេះ មានន័យថាការខាតបង់ជាក់ស្តែងអាចមានលក្ខណៈខុសគ្នាពីការប៉ាន់ស្មាន។

## ៥. ចំណូល

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលបានមកពី កិច្ចសន្យាជាមួយអតិថិជន | | | | |
| ការលក់ទំនិញ | ២៨៥.០៤៩.៩៨៩ | ១.១៦២.១៤៨.៨០៥ | ២៧៥.៣៧៣.៣៩៣ | ១.១១៥.៨១២.៧៨៦ |
| ចំណូលពីសេវាកម្ម | ៨.១២៥.៥០៥ | ៣៣.១៤៣.៩៩២ | ៨.០៥៧.៩៩៨ | ៣២.៧៧២.៥៧៨ |
| | ២៩៣.១៧៥.៤៩៤ | ១.១៩៥.២៩២.៧៩៧ | ២៨៣.៤៣១.៣៩១ | ១.១៤៨.៥៨៥.៣៦៤ |
| ពេលវេលានៃប្រាក់ចំណូល នៅចំនុចមួយនៃពេលវេលា | ២៩៣.១៧៥.៤៩៤ | ១.១៩៥.២៩២.៧៩៧ | ២៨៣.៤៣១.៣៩១ | ១.១៤៨.៥៨៥.៣៦៤ |

## ៦. ចំណូលផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ២០២.៣៨៤ | ៨២៥.១៥០ | ៤១០.០២៦ | ១.៦៦០.៥៥៥ |
| ចំណេញទទួលបានពីការលក់ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦៨.០៧៨ | ២៧៦.៧៨៤ | ៥៧.៤៥៨ | ២៣២.៧០២ |
| ចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណ | | | | |
| - ទទួលស្គាល់ | ៦៧.៨៦១ | ២៧៥.៦០៥ | ៧.០៩១ | ២៨.៦៩២ |
| - មិនទទួលស្គាល់ | ៦៣៣ | ១.៧៥៩ | ៤.៧៥៣ | ១៩.២៥១ |
| ការលើកទឹកចិត្តដល់អ្នកផ្គត់ផ្គង់ | ៩៧១.១៩១ | ៤.០០០.៣១៦ | ២៥៩.៦២១ | ១.០៥១.៤៦៥ |
| ចំណាយផ្សេងៗ | ១.៨០០ | ៧.៣៣៩ | ២៣.០៦០ | ៩៣.៣៩៨ |
| | ១.៣១១.៩៤៧ | ៥.៣៨៦.៩៥៣ | ៧៦២.០០៩ | ៣.០៨៦.០៦៣ |

## ៧. ប្រាក់ចំណេញមុនបង់ពន្ធ

ប្រាក់ចំណេញមុនបង់ពន្ធកើតឡើងបន្ទាប់ពីចំណាយទាំងនេះ៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| (ក) ចំណាយហិរញ្ញវត្ថុ | | | | |
| ការប្រាក់លើបំណុល | | | | |
| - កម្ចីពីធនាគារ | ២.១២២.២៩១ | ៨.៦៥២.៥៨០ | ២.០៣១.៣៤៦ | ៨.២៣១.០៥៤ |
| - បំណុលភតិសន្យាកម្ម | ១.១៦៩.៩១៩ | ៤.៧៦៩.៧៦០ | - | - |
| - បំណុលភតិសន្យា | ៣៣២.៤២២ | ១.៣៥៥.២៨៤ | ៣៣៦.៥៣៤ | ១.៣៦៣.៦៣៦ |
| | ៣.៦២៤.៦៣២ | ១៤.៧៧៧.៦២៤ | ២.៣៦៧.៨៨០ | ៩.៥៩៤.៦៩០ |

## ៧. ប្រាក់ចំណេញមុនបង់ពន្ធ (ត)

ប្រាក់ចំណេញមុនបង់ពន្ធកើតឡើងបន្ទាប់ពីចំណាយទាំងនេះ៖ (ត)

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| (ខ) បរិក្ខារផ្សេងៗ | | | | |
| ការរំលស់នៃទ្រព្យអរូបី | - | - | ៤.៧៧៦ | ១៩.៣៥២ |
| កម្រៃរបស់សវនករ | ៤៧.២៩៨ | ១៩២.៨៣៤ | ៥៧.៨៣៨ | ២៣៤.៣៦០ |
| ការរំលស់នៃ | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ២.២១៥.២៤៨ | ៩.០៣១.៨៩១ | ១.៩៩៥.៦១៩ | ៨.០៨៦.២៤៨ |
| ការរំលស់សិទ្ធិ | | | | |
| ក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ៨៧៥.៣២២ | ៣.៥៩០.៦៧៧ | ៨៦២.៩៤៥ | ៣.៤៩៦.៦៨៣ |
| កំរៃនាយក | ៣៧.២៥៤ | ១៥១.៨៨៨ | ៦៣.៧៦៥ | ២៥៨.៣៧៦ |
| ការចំណាយលើអត្ថប្រយោជន៍ | | | | |
| និយោជិក (កំណត់សម្គាល់ ៩) | ៦.៦៤៩.១១៣ | ២៧.១០៨.៨៣៤ | ៥.២៦៨.២២១ | ២១.៣៣០.៦២៣ |
| ការថយចុះតម្លៃនៃ | | | | |
| គណនីអតិថិជនពាណិជ្ជកម្ម | ៥៥២.៧៥៤ | ២.២៥៣.៧៤១ | ៥៩០.០៥៦ | ២.៣៩១.០៦៩ |
| ការចំណាយលើការជួល | | | | |
| - ការជួលទ្រព្យសកម្មដែលមានតម្លៃទាប | | | | |
| មិនរួមបញ្ចូលការជួលរយៈពេលខ្លី | | | | |
| ខ្លីនិងទ្រព្យសកម្មដែលមានតម្លៃទាប | ១២.៨៤៦ | ៥២.៣៧៣ | ៥.៥២១ | ២២.៣៧១ |
| ប្រាលប់នៃប្រូសវិធានធន | | | | |
| សម្រាប់សន្និធិដែលធ្វើចលនាយឺត | (២៧១.៤៥២) | (១.១០៦.៨៣២) | ១.៥៦៤.៩៤៨ | ៦.៣៣៩.១៩២ |
| ការលុបចោលនៃ: | | | | |
| - ទ្រព្យសកម្មអរូបី | - | - | ១៥.២១៨ | ៦០.៥៦៨ |

## ៨. ពន្ធលើប្រាក់ចំណូល

ការចំណាយពន្ធដែលបង្កឡើងដោយប្រាក់ចំណេញរួមមាន៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ពាន់រៀល (កំណត់ឡើងវិញ) |
| ពន្ធលើប្រាក់ចំណូល | | | | |
| - ឆ្នាំបច្ចុប្បន្ន | ៧.៥៤១.៥៦៥ | ៣០.៧៤៨.៥៩១ | ៦.១៥២.១៩៥ | ២៤.៩២៨.៦៩៤ |
| - កត់ត្រាក្រោមសំវិធានធននៅឆ្នាំចាស់ | - | - | ៤១៥.៥៧៥ | ១.៦៨៣.៩១០ |
| ការលើកទឹកចិត្តពន្ធដារ | (១.៥៧៧.៧៥០) | (៨.០០០.០០០) | - | - |
| ពន្ធពន្យារ | (២.២៤២.២៦៩) | (៩.០២២.៤៤៨) | (៩៤៨.៦៣៥) | (៣.៨៤៤.៦៦០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១៨២.៤៦៩) | - | ៤០.៧៩១ |
| | ៣.៧២១.៥៤៦ | ១៣.៥៤៣.៦៧៤ | ៥.៦១៩.១៣៥ | ២២.៧៦៨.៧៣៥ |

## អេ អិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

### ៨. ពន្ធលើប្រាក់ចំណូល (ត)

ការចំណាយពន្ធលើលទ្ធផលនៃឆ្នាំហិរញ្ញវត្ថុខុសគ្នាពីចំនួនពន្ធលើប្រាក់ចំណូល ដែលបានកំណត់ដោយការអនុវត្តអត្រាពន្ធលើប្រាក់ចំណូលដែលត្រូវបានកំណត់ដោយគណនាខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ពាន់រៀល (កំណត់ឡើងវិញ) |
| ចំណេញមុនបង់ប្រាក់ពន្ធ | ២៧.១២៨.២១៦ | ១១០.៦០១.៧៣៧ | ២៧.៨៣៥.៥៩២ | ១១៣.៣៩៣.៦១៨ |
| ប្រាក់ពន្ធបានគណនាតាមអត្រា ២០% | ៥.៤២៥.៦៤៣ | ២២.១២០.៣៤៧ | ៥.៥៦៧.១១៨ | ២២.៦៧៨.៧២៤ |
| ផលប៉ះពាល់នៃចំណាយដែលមិនអាចកាត់កងបាន សម្រាប់គោលបំណងពន្ធ | ២.១១៦.៣២២ | ៨.៦៤៥.៧៨៥ | ៥៥៥.០៧៧ | ២.២៥៩.៥៦១ |
| ដើមទុននៃអាជ្ញាប័ណ្ណធនាគារសន្សំ | (២.២៤២.២៦៥) | (៩.០២២.៩៤៨) | (៩៥៨.៦៣៥) | (៣.៨៨៤.៦៦០) |
| កត់ត្រាក្រោមសំវិធានធននៅឆ្នាំចាស់ | - | - | ៤១៥.៨៧៥ | ១.៦៨៣.៥១០ |
| ការលើកទឹកចិត្តពន្ធដារ | (១.៩៧៧.៧៥០) | (៨.០០០.០០០) | - | - |
| | ៣.៣២១.៩៥០ | ១៣.៥៤៣.៩៧៤ | ៥.៦១៩.១៣៥ | ២២.៧៣៦.៧៣៥ |
| ពន្ធពន្យារ៖ | | | | |
| ដើមទុននៃអាជ្ញាប័ណ្ណធនាគារសន្សំ | ៣.១៥០.៥០៤ | ១២.៥០៧.២០៨ | ៩៥៨.៦៣៥ | ៣.៨៨៤.៦៦០ |

* ដោយអនុលោមតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ និងប្រកាសលេខ ១៨៣ ស្តីពីការអនុវត្តការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល សម្រាប់អង្គភាពដែល ផ្តល់មូលបត្រជូនសាធារណៈជន អង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងទទួលបានការលើកទឹកចិត្តពន្ធដារដូចខាងក្រោម ដែលតម្រូវអោយមានការយល់ព្រមពីអាជ្ញាធរពាក់ព័ន្ធ៖

- សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំលើសពី ២០ភាគរយ នៃសិទ្ធិបោះឆ្នោត និង/ឬបោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០ភាគរយនៃទ្រព្យសកម្មសរុប និងមានគណៈប្រតិភូយ៉ាងតិច ៧ឆ្នាំ នឹងទទួលបានការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់សម្រាប់រយៈពេល ៣ឆ្នាំ។
- សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំលើសពី ២០ភាគរយ នៃសិទ្ធិបោះឆ្នោត និង/ឬបោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០ភាគរយនៃទ្រព្យសកម្មសរុបនឹងទទួលបានការលើកទឹកចិត្តពន្ធដារ នៃពន្ធលើប្រាក់ចំណូលត្រូវបង់សម្រាប់រយៈពេល ៣ឆ្នាំតាមសមាមាត្រ។ ការលើកទឹកចិត្តពន្ធដារទាំងនេះត្រូវបានកំណត់ត្រឹម ២០.០០០.០០០.០០០ រៀល និង ៨.០០០.០០០.០០០.០០០ រៀល សម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលរៀងៗខ្លួន។

# អេ អិម អេ (ខេមបូឌា) ម.ក
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ៨. ពន្ធលើប្រាក់ចំណូល (ត)

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ អគ្គនាយកដ្ឋានពន្ធដារ ("GDT") និងគណៈកម្មការមូលបត្រនៃកម្ពុជា (គ.ម.ក) បានបញ្ជាក់ និងផ្តល់ដល់ក្រុមហ៊ុននូវការលើកទឹកចិត្តពន្ធដារសម្រាប់រយៈពេល ៣ឆ្នាំដោយចាប់ផ្តើមពីការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ បន្ទាប់មក ក្រុមហ៊ុនបានទទួលស្គាល់ផលប៉ះពាល់នៃការលើកទឹកចិត្តពន្ធដារទាំងនេះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ដែលផ្ទុយពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នរបស់ខ្លួនសម្រាប់ត្រីមាស និងរយៈពេល ១២ខែ បញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ ។

## ៩. ការចំណាយលើអត្ថប្រយោជន៍និយោជិក

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ឈ្នួល និង ប្រាក់ខែ | ៥.៩៦៣.៥៤៩ | ២៤.៣១៣.៣៩០ | ៤.៥៩៤.៤៤៥ | ១៨.៦១៦.៦៩១ |
| អត្ថប្រយោជន៍ផ្សេងៗ | ៦៨៥.៥៦៤ | ២.៧៩៥.០៤៤ | ៦៦៩.៧៧៦ | ២.៧១៣.៩៣២ |
| | ៦.៦៤៩.១១៣ | ២៧.១០៨.៤៣៤ | ៥.២៦៤.២២១ | ២១.៣៣០.៦២៣ |

## ១០. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | អគារ ដុល្លារអាមេរិក | ឧបករណ៍សម្រាប់ សេវាកម្ម និង បរិក្ខារឃ្លាំង ដុល្លារអាមេរិក | សម្ភារ និង បរិក្ខារបំពាក់ ដុល្លារអាមេរិក | ការកែលម្អ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | ឧបករណ៍ សម្រាប់ ប្រតិបត្តិការ ដុល្លារអាមេរិក | កុងតឺន័រ ដុល្លារអាមេរិក | ទ្រព្យសកម្ម កំពុង សាងសង់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ៤.៤៨៩.២៩៨ | ១.០៧០.២២៦ | ៩០២.៦៣០ | ១.៩៩០.៧៥៣ | ៤.១១២.៣១២ | ២.០៩៩.២៤៤ | ៣១.៩៥២ | ៩៩.៩១០ | ១៤.៨៨៣.៩២៨ |
| ការទិញបន្ថែម | - | ៣៣.៨៤៨ | ៧.៦៣៩ | ៦៣.៦២៦ | ៤.០២៨.៨០៤ | ៨០៦.០៣៩ | - | ៨២៧.៧៨៨ | ៤.៩២៧.៨០៤ |
| ការលក់ | (២៩.១៨៤) | (១១.៨៥៦) | (៩.២៣២) | (៨៤.៩២៨) | (១.៨៣១.២៣១) | (៨២២.៨៨៨) | - | - | (២.៣៨៨.៦១៩) |
| ការលុបចោល | - | - | - | - | - | - | - | - | - |
| ការផ្ទេរ | ៣១.៩៥២ | - | ១.៣៨៦ | ២៩.៨៦៦ | - | ១៩.២៩៨ | (៣១.៩៥២) | (៥០.១១០) | - |
| **សមតុល្យ** | | | | | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩/ នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ៤.៤៨៨.០៩៦ | ១.០៥២.១៨៨ | ៩០២.៣៨៣ | ១.៦៣៨.៩១៧ | ៦.៨០៩.៨៨៥ | ២.០៩៩.០៩៣ | - | ៨៣៣.១៩៨ | ១៧.៨២២.៧១០ |
| ការទិញបន្ថែម | ៧៧៧.៣៣១ | ៣៨៤.៦២៣ | ៩៧.៨៣៧ | ៣៤.៨៨១ | ២.៩០៩.៧០៣ | ៨៣៩.៨០១ | - | ៦៣.៩០៨ | ៤.៦៦៨.៧៨៨ |
| ការលក់ | (១៣៤.៣៧៨) | (១៣៩.៩៣៨) | (១៣.៣២២) | (១០.៨៩៤) | (២.៣៦៤.៧៨៣) | (៩៨១.៧០៦) | - | - | (៣.២០៤.២១៨) |
| ការផ្ទេរ | ២៣៩.២៧៩ | ១២២.៨៥៦ | - | - | - | ១៧.៨០០ | - | (៣៧៩.១៣៥) | - |
| **សមតុល្យ** | | | | | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៥.៣៧០.៣៣១ | ១.៤២៣.៧៣៣ | ៩៨៦.៨៩៨ | ១.៦៦៤.៣០៤ | ៦.៨៨៨.៨០៤ | ២.៨០៩.៨៨៨ | - | ១១៧.៩២១ | ១៨.៩២៧.២៨០ |

# អេ អិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ១០. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | អគារ ដុល្លារអាមេរិក | ឧបករណ៍ សម្រាប់ សេវាកម្ម និង បរិក្ខារម៉ាស៊ីន ដុល្លារអាមេរិក | សម្ភារៈ និង បរិក្ខារបំពាក់ ដុល្លារអាមេរិក | ការកែលំអរ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | ឧបករណ៍ សម្រាប់ ប្រតិបត្តិការ ដុល្លារអាមេរិក | កុងតឺន័រ ដុល្លារអាមេរិក | ទ្រព្យសកម្ម កំពុង សាងសង់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|---|
| **ថ្លៃដើមបង្គរ** | | | | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ១.៦៥២.៩៩៧ | ៧៥១.០៧៨ | ៧៩៩.៦៣២ | ១.១៣៨.៩៦៦ | ១.៧២៥.៣០៥ | ១.៩៩៩.៥៦១ | ៣១.៩៥២ | - | ៧.៦២៩.៣៩១ |
| ថ្លៃរំលស់ | ៣៣៤.៣៦៥ | ១១២.៦២៧ | ៥៥.៣៥៦ | ១៩៥.៦៥២ | ១.០២៧.១៩២ | ២៦៣.៤២៧ | - | - | ១.៩៩៥.៦១៩ |
| ការលក់ | (១៥.៧៧៤) | (១០.៣៤៣) | (៩.០១២) | (៤៤.៩២៧) | (៧៣៥.៧៩០) | (២៧៤.៨៧៥) | - | - | (១.០៩០.៧៣១) |
| ការផ្ទេរ | ៣១.៩៥២ | - | - | - | - | - | (៣១.៩៥២) | - | - |
| សមតុល្យ | | | | | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩/ នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ២.០០៧.០៩០ | ៨៥៣.៣៨៨ | ៨៤៥.៩៧៦ | ១.២៥២.៦៩១ | ២.០១៧.១១១ | ១.៥៥៨.១១៣ | - | - | ៨.៥៣៤.២៧៩ |
| ថ្លៃរំលស់ | ៣៩០.៥៩០ | ១២៧.១០៤ | ២៧.០៧៨ | ១៦៤.៥៣៣ | ១.២១៧.៤៥២ | ២៥៧.៩០៧ | - | - | ២.២១៩.២៥៤ |
| ការលក់ | (៧៦.៥៧០) | (១៣៩.៤១៩) | (១៣.៣២២) | (៩.៥៣៣) | (៥៣៥.២០២) | (១៣០.៣៥២) | - | - | (១.២០៤.៧៥៣) |
| សមតុល្យ | | | | | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ២.៣២១.៣២០ | ៨៧១.០៣៨ | ៨៥៩.៧៣២ | ១.៥៥៧.៦៩១ | ២.៣៩៩.៥៥១ | ១.៦៨៥.៦៦៨ | - | - | ៩.៥៥៤.៧៩០ |

# អេ អិម អេ (ខេមបូឌា) ម.ក

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ១០. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | អាគារ<br>ដុល្លារអាមេរិក | ឧបករណ៍សម្រាប់សេវាកម្ម និងបរិក្ខារឃ្លាំង<br>ដុល្លារអាមេរិក | សម្ភារៈ និងបរិក្ខារបំពាក់<br>ដុល្លារអាមេរិក | កាកែលំអ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | ឧបករណ៍សម្រាប់ប្រតិបត្តិការ<br>ដុល្លារអាមេរិក | កុងតឺន័រ<br>ដុល្លារអាមេរិក | ទ្រព្យសកម្មកំពុងសាងសង់<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|---|
| **តម្លៃយោង** | | | | | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩<br>ដុល្លារអាមេរិក | ២.៤៩១.០៥៦ | ២០៨.៨៤០ | ៩៦.៤០៧ | ៣៩៦.២២៦ | ៤.៧៥២.៧៨៤ | ៦០៩.៩៤០ | - | ៤៣៣.១៨៨ | ៨.៩២៨.៨៣១ |
| ពាន់រៀល | ១០.១១០.៣០៣ | ៨៩១.០២៣ | ២២៩.៨៥៩ | ១.៩១០.៨៧១ | ១៩.៨៣០.៥៥៨ | ២.៨៥៩.៦៦៩ | - | ១.៧៦៥.០៧៨ | ៣៦.៣៨៣.៣៩៦ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០<br>ដុល្លារអាមេរិក | ៣.០៥៨.៩៧១ | ៥៥៦.៦៥៥ | ១២៦.៨៦៦ | ២១១.៣១៣ | ៤.៨៥៥.៨៥៤ | ៧២៣.៩១០ | - | ១១៣.៩២១ | ៩.៣៨២.៨៣០ |
| ពាន់រៀល | ១២.៣៣៣.០៨៨ | ២.២៣៨.៦៨១ | ៥១៣.១៧៣ | ៨៧៤.៩៥៦ | ១៨.៩២៨.៩២៥ | ៣.០៩០.០១៦ | - | ៨៧៦.៩៩០ | ៣៧.៩៩៦.៣៣៤ |

## ១១. សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម

ក្រុមហ៊ុនជួលបន្ទប់តាំងបង្ហាញ និងឃ្លាំងស្តុកទំនិញ។ ការជួលជាធម្មតាមានរយៈពេល ១៥ឆ្នាំហើយមានជម្រើសក្នុងការបន្តជួលបន្តបន្ទាប់ពីកាលបរិច្ឆេទនោះ។ ការបង់ថ្លៃជួលត្រូវបានចរចាឡើងវិញនៅចុងបញ្ចប់នៃរយៈពេលជួលដើម្បីឆ្លុះបញ្ចាំងពីតម្លៃទីផ្សារនៃការជួល។ ចំពោះភតិសន្យាជាក់លាក់ ក្រុមហ៊ុនមិនត្រូវបានអនុញ្ញាតឱ្យធ្វើកិច្ចសន្យាជួលបន្តឡើយ។

បន្ទប់តាំងបង្ហាញ និងឃ្លាំងជួលត្រូវបានជួលជាច្រើនឆ្នាំមកហើយដោយបានធ្វើកិច្ចសន្យាជួលដី និងអគាររួមគ្នា។

ព័ត៌មានអំពីភតិសន្យាដែលក្រុមហ៊ុនបានជួលមានដូចខាងក្រោម៖

<u>សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម</u>

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា | ៣.៨១៥.១៩៩ | ១៥.៥៤៦.៥៣៦ | - | - |
| បន្ថែមសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ៧០១.៦៨៧ | ២.៨៣៨.៣២២ | ៤.៦៧៨.១៤៤ | ១៩.០៦៣.៤៣៧ |
| រំលស់ | (៨៧៥.៣២២) | (៣.៥៤០.៦៧៧) | (៨៦២.៩៤៥) | (៣.៥១៦.៦៥៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១១៤.៤៥៥) | - | (១៩.៤៤៨) |
| | ៣.៦៤១.៥៦៤ | ១៤.៧៣០.១២៦ | ៣.៨១៥.១៩៩ | ១៥.៥៤៦.៥៣៦ |

## ១២. ទ្រព្យសកម្មពន្ធពន្យារ, សុទ្ធ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ពាន់រៀល (កំណត់ឡើងវិញ) |
| ទ្រព្យសកម្មពន្ធពន្យារ | ៣.៩២៥.៦៥៧ | ១៥.៨៧៩.២៨៤ | ១.៤៩៤.១៥៤ | ៦.០៥៥.១០៣ |
| បំណុលពន្ធពន្យារ | (៧៣៤.៧៥៣) | (២.៩៧២.០៧៦) | (៥៤៩.៥១៩) | (២.២១០.៤៤៣) |
| ទ្រព្យសកម្មពន្ធពន្យារ, សុទ្ធ | ៣.១៩០.៩០៤ | ១២.៩០៧.២០៨ | ៩៤៤.៦៣៥ | ៣.៨៤៤.៦៦០ |

ចលនានៃពន្ធពន្យារទ្រព្យសកម្មក្នុងតំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក (កំណត់ឡើងវិញ) | ពាន់រៀល (កំណត់ឡើងវិញ) |
| នាដើមការិយបរិច្ឆេទ | ៩៤៤.៦៣៥ | ៣.៨៤៤.៦៦០ | - | - |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | ២.២៤៦.២៦៩ | ៩.០៦២.៥៤៨ | ៩៤៤.៦៣៥ | ៣.៨៤៤.៦៦០ |
| នាចុងការិយបរិច្ឆេទ | ៣.១៩០.៩០៤ | ១២.៩០៧.២០៨ | ៩៤៤.៦៣៥ | ៣.៨៤៤.៦៦០ |

## ១២. ពន្ធពន្យារទ្រព្យសកម្មសុទ្ធ (ក)

ពន្ធពន្យារទ្រព្យសកម្ម និងបំណុលត្រូវបានទូទាត់សង នៅពេលដែលក្រុមហ៊ុនមានសិទ្ធធ្វើការកាត់កងតាមច្បាប់ នូវពន្ធលើទ្រព្យសកម្ម ជាមួយនឹងបំណុលពន្ធបច្ចុប្បន្ន និងនៅពេលដែលពន្ធពន្យារមានជាប់ទាក់ទងនឹងសារពើពន្ធក្នុងឆ្នាំដដែល។

| | ១ មករា ២០១៩<br>ដុល្លារអាមេរិក | ទទួលស្គាល់ក្នុងចំណូលឬចំណាយប្រចាំឆ្នាំ<br>ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៩<br>ដុល្លារអាមេរិក | ទទួលស្គាល់ក្នុងចំណូលឬចំណាយប្រចាំឆ្នាំ<br>ដុល្លារអាមេរិក | ៣១ ធ្នូ ២០២០<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|
| ពន្ធពន្យារទ្រព្យសកម្ម | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | - | (៨៤៥.៥១៩) | (៨៤៥.៥១៩) | (៨៨៧.៨០២) | (១.៧៣៣.៣២១) |
| សំវិធានធន | - | ១.៤៩៣.១៨៦ | ១.៤៩៣.១៨៦ | ៨៤២.១៧៤ | ២.៣៣៥.៣៦០ |
| កិច្ចសន្យាបំណុល | - | - | - | ១.៥៨៤.៨៨៨ | ១.៥៨៤.៨៨៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ មិនទាន់បានទទួលស្គាល់ | - | ៥៥៥ | ៥៥៥ | ៣.៨០៩ | ៤.៣៦៤ |
| | - | ៥៤៨.៦៣៨ | ៥៤៨.៦៣៨ | ២.២៤២.២៦៩ | ៣.១៩០.៩០៧ |
| ពាន់រៀល | - | ៣.៨៨៤.៦៦០ | ៣.៨៨៤.៦៦០ | ៩.០២២.៥៨៨ | ១២.៩០៧.២០៨ |

## ១៣. ទ្រព្យសកម្មអរូបី

| | ២០២០<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល | ២០១៩<br>ដុល្លារអាមេរិក | ២០១៩<br>ពាន់រៀល |
|---|---|---|---|---|
| **សិទ្ធប្រើប្រាស់លើទីតាំងពិសេស** | | | | |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី១ ខែមករា | - | - | ៤៦.០០០ | ១៨៤.៨២៨ |
| លុបចោល | - | - | (៤៦.០០០) | (១៨៤.៨២៨) |
| នាថ្ងៃទី៣១ ខែធ្នូ | - | - | - | - |
| | | | | |
| **រលស់បង្គរ** | | | | |
| នាថ្ងៃទី១ ខែមករា | - | - | ២៦.០១០ | ១០៤.៥០៨ |
| ថ្លៃរំលស់ | - | - | ៤.៧៧៦ | ១៩.៣៥២ |
| លុបចោល | - | - | (៣០.៧៨៦) | (១២៣.៨៦០) |
| នាថ្ងៃទី៣១ ខែធ្នូ | - | - | - | - |
| | | | | |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី៣១ ខែធ្នូ | - | - | - | - |

ថ្លៃរំលស់ មិនមាន (២០១៩: ៤.៧៧៦ ដុល្លារអាមេរិក (១៩.៣៥២.០០០ រៀល)) ត្រូវបានកត់ត្រាក្នុងចំណាយប្រតិបត្តិការ។

## ១៤. សន្និធិ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការផ្គត់ផ្គង់ទំនិញ និងគ្រឿងបន្លាស់ | ៤០.១៥៨.៧០៦ | ១៦២.២០៣.៧៦៦ | ៧៧.៤៧៨.២៥៤ | ៣១៧.៣៥៤.០៤៨ |
| សំវិធានធនសម្រាប់សន្និធិយឺត | (២.៣៤៤.៥៩១) | (៩.៦៤៥.៦៩៩) | (២.៦៥៦.០៧៣) | (១០.៨២៣.៤៥៧) |
| | ៣៧.៨១៤.១១៥ | ១៥២.៥៥៨.០៦៧ | ៧៤.៨២២.១៨១ | ៣០៦.៥៣០.៥៩១ |

ថ្លៃដើម រួមមានថ្លៃដើមសន្និធិដែលបានលក់ក្នុងកំឡុងការិយបរិច្ឆេទ ថ្លៃពលកម្ម និងថ្លៃដើមផ្សេងៗទៀត។ ថ្លៃដើមសម្រាប់ការិយបរិច្ឆេទមានចំនួន ២៤៦.៨៧៧.០០៧ ដុល្លារអាមេរិក (១.០០៧.១៥៥.៣២៣.០០០ រៀល) (២០១៩ : ២៣៧.០៧៥.៨៩៣ ដុល្លារអាមេរិក (៩៦០.៦៣១.៥១៨.០០០ រៀល)) ។

ថ្លៃដើមសន្និធិរបស់ក្រុមហ៊ុន ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងថ្លៃដើមទំនិញដែលបានលក់នៅក្នុងកំឡុងការិយបរិច្ឆេទ ដោយសារការលុបចោលសន្និធិនៅតម្លៃពិតប្រាកដគឺ មិនមាន (២០១៩ : ១.៥៦៤.៨៤៨ (៦.៣៣៩.១៤២.០០០ រៀល))។

ក្នុងកំឡុងការិយបរិច្ឆេទ ក្រុមហ៊ុនបានត្រលប់ការលុបចោលសន្និធិពីមុនដែលមានចំនួន ២៧១.៤៥២ ដុល្លារអាមេរិក (១.១០៦.៨៣២រៀល) (២០១៩ : គ្មាន) ដោយសារក្រុមហ៊ុនអាចលក់ទំនិញដែលលែងប្រើប្រាស់បានទាំងនោះនៅក្នុងឆ្នាំ។

## ១៥. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **គណនីអតិថិជនពាណិជ្ជកម្មបានមកពីកិច្ចសន្យាជាមួយអតិថិជន** | | | | |
| ភាគីទីបី | ៦.៣៦២.២៣៨ | ២៥.៧៣៥.២៥៣ | ៥.៧៩៣.៦១៦ | ២៣.៦០៨.៩៥៥ |
| សំវិធានធនសម្រាប់ការធ្លាក់ចុះតម្លៃនៃគណនីពាណិជ្ជកម្ម | (១.១៧២.០៦៦) | (៤.៧៤១.០០៧) | (៦១៩.២៧២) | (២.៥២៣.៥៣៣) |
| | ៥.១៩០.១៧២ | ២០.៩៩៤.២៤៦ | ៥.១៧៤.៣៤៤ | ២១.០៨៥.៤២២ |
| **គណនីអតិថិជនផ្សេងៗ** | | | | |
| គណនីអតិថិជនផ្សេងៗ | ២៤៣.៩៥១ | ៩៨៦.៧៨២ | ៦៨៦.៤២៦ | ២.៧៩៧.១៨៦ |
| ចំណាយបង់មុន | ១.២៦៤.១៣១ | ៥.១១៣.៤០៩ | ២៩៧.៥៦៣ | ១.២១២.៥៦៩ |
| ប្រាក់កក់ | ៣៥៥.២៣៦ | ១.៤៣៦.៩៣០ | ៣៦០.៦៦៦ | ១.៤៦៩.៧១៤ |
| ពន្ធត្រូវទទួលផ្សេងៗ | - | - | ២.០១៥.៧៤១ | ៨.២១៤.១៤៥ |
| | ១.៨៦៣.៣១៨ | ៧.៥៣៧.១២១ | ៣.៣៦០.៣៩៦ | ១៣.៦៩៣.៦១៤ |
| | ៧.០៥៣.៤៩០ | ២៨.៥៣១.៣៦៧ | ៨.៥៣៤.៧៤០ | ៣៤.៧៧៩.០៣៦ |

**អេ អិម អេ (ខេមបូឌា) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ១៥. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ (ត)

រាល់គណនីពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗត្រូវរំពឹងថានឹងអាចប្រមូលបានមកវិញឬទទួលស្គាល់ជាចំណាយក្នុងរយៈពេលមួយឆ្នាំ។

(ក) ទម្រង់អាយុកាល

ទម្រង់អាយុកាលនៃគណនីអតិថិជនពាណិជ្ជកម្មមានដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មិនហួសកាលកំណត់ និងមិនថយចុះតម្លៃ | ៤.០៩៩.៦៣៥ | ១៦.៥៨៣.០២៤ | ២.៧៦៩.២៦០ | ១១.២៨៤.៧៣៤ |
| ហួសកាលកំណត់តែមិនថយចុះតម្លៃ | | | | |
| - ហួសកាលកំណត់តិចជាងបីខែ | ៦០៤.៣៦៦ | ២.៤៤៤.៦៦០ | ១.៤០៨.៨៣៥ | ៥.៧៤១.៤១០ |
| - ហួសកាលកំណត់ច្រើនជាងបីខែ តែតិចជាង១២ខែ | ៤៨៦.១៧១ | ១.៩៦៦.៥៦២ | ៩២៤.៤៤៥ | ៣.៧៦៧.១៣០ |
| - ហួសកាលកំណត់ច្រើនជាង១២ខែ | - | - | ៧១.៧០០ | ២៩២.១៧៨ |
| | ៥.១៩០.១៧២ | ២០.៩៩៤.២៤៦ | ៥.១៧៤.៣៤៤ | ២១.០៨៥.៤៥២ |
| **ការថយចុះនៃតម្លៃ** | | | | |
| ឯកបុគ្គល | ១.១៧២.០៦៦ | ៤.៧៤១.០០៧ | ៦១៩.២៧២ | ២.៥២៣.៥៣៣ |
| | ៦.៣៦២.២៣៨ | ២៥.៧៣៥.២៥៣ | ៥.៧៩៣.៦១៦ | ២៣.៦០៨.៩៨៥ |

ជាធម្មតាគណនីត្រូវទទួលគឺត្រូវបានទូទាត់ក្នុងកំឡុងពេល៣០ថ្ងៃ ពីថ្ងៃចេញវិក្កយប័ត្រ។

(ខ) ការថយចុះតម្លៃនៃគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

ការខាតបង់លើការថយចុះនៃតម្លៃដែលទាក់ទងនឹងគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ត្រូវបានកត់ត្រាដោយប្រើគណនីសំវិធានធនលើការថយចុះនៃតម្លៃ លុះត្រាតែក្រុមហ៊ុនពេញចិត្តថាមិនមានលើមធ្យោបាយណាដែលអាចប្រមូលបានមកវិញ ក្នុងករណីនេះការខាតបង់លើការថយចុះនៃតម្លៃត្រូវបានលុបចេញពីបញ្ជី ដោយផ្ទាល់ដោយធៀបនឹងគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ។

## ១៥. គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ (ត)

(ខ) ការថយចុះតម្លៃនៃគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ (ត)

ការផ្លាស់ប្តូរនៅក្នុងគណនីសំវិធានធនលើឱនភាពនៃឱនភាពតម្លៃប្រចាំឆ្នាំគឺមានដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា | ៦១៩.២៧២ | ២.៥២៣.៥៣៣ | ៥៦.៥១២ | ២២៧.០៦៤ |
| ការបាត់បង់នៃការថយចុះនៃតម្លៃដែលបានទទួលស្គាល់ | | | | |
| - ការវាយតម្លៃតាមបុគ្គល | ៥៥២.៧៩៤ | ២.២៥៣.៧៤១ | ៥៩០.០៩៦ | ២.៣៩១.០៦៩ |
| ផ្សេងៗ | - | - | (២៧.៣៣៦) | (១១០.៧៦៥) |
| លម្អៀងលើការប្តូររូបិយប័ណ្ណ | - | (៣៦.២៦៧) | - | ១៦.១៦៤ |
| នាថ្ងៃទី៣១ ខែធ្នូ | ១.១៧២.០៦៦ | ៤.៧៤១.០០៧ | ៦១៩.២៧២ | ២.៥២៣.៥៣៣ |

## ១៦. ទឹកប្រាក់ជំពាក់ពី/ (ទៅ) ភាគីពាក់ព័ន្ធ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធ** | | | | |
| - ក្រុមហ៊ុនពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម | ៣.១៣១.៨៥៣ | ១២.៦៦៨.៥០៧ | ១៣.២៤១.៥០៧ | ៥៣.៩៥០.៧៧១ |
| **ទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនពាក់ព័ន្ធ** | | | | |
| - ក្រុមហ៊ុនកាន់កាប់ផ្ទាល់ភាគហ៊ុនដែលគ្រប់គ្រង | - | - | ២.៥៨០.០០០ | ១០.៥១៣.៥០០ |
| - ក្រុមហ៊ុនពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម | ៥៤៦.១៦៩ | ២.២០៩.២៥៤ | ៤.២៣៤.៥៨៩ | ១៧.២៥៧.៥៨០ |
| | ៥៤៦.១៦៩ | ២.២០៩.២៥៤ | ៦.៨១៤.៥៨៩ | ២៧.៧៧១.០៨០ |

សមតុល្យពាណិជ្ជកម្មគឺអាស្រ័យលើលក្ខខណ្ឌពាណិជ្ជកម្មធម្មតា។

ទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធមានចំនួន ២.០៣៣.៨៤៨ ដុល្លារអាមេរិក (៨.២២៦.៩១៥.០០០ រៀល) (២០១៩ : ១២.៣៧២.៧៦៦ ដុល្លារអាមេរិក (៥០.៤១៩.០២១.០០០ រៀល)) ត្រូវបានរួមបញ្ចូលក្នុងទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធខាងលើ។ ចំនួននេះជាសមតុល្យពាណិជ្ជកម្មនេះដែលគ្មានទ្រព្យបញ្ចាំ សងត្រលប់តាមតម្រូវការនិងមិនមានការប្រាក់ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ តទៅ។ អត្រាការប្រាក់ប្រសិទ្ធភាពនៃទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ទៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ គឺ ៣.៦០% (២០១៩ : ៤.៨៩%)។

## ១៧. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់នៅធនាគារ និងនៅក្នុងដៃ | ៣៩.៣៥២.៧៦៦ | ១៥៩.១៨១.៩៣៨ | ១០.៩៥៥.២១៩ | ៤៤.៦៤២.៥១៧ |

ក្នុងគោលបំណងបង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់នៅធនាគារ និងនៅក្នុងដៃ | ៣៩.៣៥២.៧៦៦ | ១៥៩.១៨១.៩៣៨ | ១០.៩៥៥.២១៩ | ៤៤.៦៤២.៥១៧ |
| មូលបត្របំណុលធានាដោយ CGIF | (១.០៨១.៨៧៩) | (៤.៣៦៧.២០១) | - | - |
| | ៣៨.២៧០.៨៨៧ | ១៥៤.៨១៤.៧៣៧ | ១០.៩៥៥.២១៩ | ៤៤.៦៤២.៥១៧ |

រួមបញ្ចូលនៅក្នុងសាច់ប្រាក់ និងសមតុល្យធនាគាររបស់ក្រុមហ៊ុនមានចំនួន ១.០៨១.៨៧៩ ដុល្លារអាមេរិក (៤.៣៦៧.២០១.០០០ រៀល) (២០១៩: មិនមាន) កាន់កាប់ដោយធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈស្ថាប័ន Credit Guarantee and Investment Facility ("CGIF") ជាការធានាលើមូលបត្របំណុល ដូចបានបង្ហាញនៅកំណត់សម្គាល់ ២០(ខ) នៃរបាយការណ៍ហិរញ្ញវត្ថុ ហើយទឹកប្រាក់នេះមិនមែនសម្រាប់ប្រើប្រាស់ទូទៅដោយក្រុមហ៊ុនទេ ។

## ១៨. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម** | | | | |
| **ភាគីទីបី** | ៣.០៦៨.៣១៧ | ១២.៤១១.៣៤២ | ៧.៥១៤.១៤១ | ៣០.៦២០.១២៤ |
| **គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ** | | | | |
| គណនីបង្គរ | ៤.១០១.៣៥៧ | ១៦.៥៩០.១៦១ | ៧.៣៥៥.០៦៧ | ២៩.៩៧១.៨៥៨ |
| ប្រាក់ពន្ធផ្សេងៗដែលត្រូវបង់ | ១.៦២៧.៥២៩ | ៦.៥៨៣.៣៨៥ | ១.០៤៧.១១១ | ៤.២៦៦.៧១៥ |
| | ៥.៧២៨.៨៨៦ | ២៣.១៧៣.៥៤៦ | ៨.៤០២.១៧៨ | ៣៤.២៣៨.៥៧៣ |
| | ៨.៧៩៧.២០៣ | ៣៥.៥៨៤.៨៨៨ | ១៥.៩១៦.៣១៩ | ៦៤.៨៥៨.៦៩៧ |

ជាធម្មតាលក្ខខណ្ឌឥណទានពាណិជ្ជកម្មដែលបានផ្តល់ឱ្យក្រុមហ៊ុនគឺក្នុងរយៈពេល ៣០ ថ្ងៃ។

## ១៩. កិច្ចសន្យាចំណូល

ចំណូលកិច្ចសន្យា ទាក់ទងនឹងការទទួលបានពីអតិថិជន និងវិក័យប័ត្រលើសពីប្រាក់ចំណូលដែលទទួលស្គាល់ របៀតមកដល់បច្ចុប្បន្ន។ ចំណូលកិច្ចសន្យា ត្រូវបានទទួលស្គាល់ថាជាប្រាក់ចំណូលនៅពេល (ឬពេលណា) ក្រុមហ៊ុនបំពេញកាតព្វកិច្ចអនុវត្តក្រោមកិច្ចសន្យា។

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី១ ខែមករា | ១៤.៦៤៥.៨៧៣ | ៥៩.៦៨១.៩៣២ | ៥.១០៣.០៦៣ | ២០.៥០៤.១០៧ |
| ដក: | | | | |
| ចំណូលទទួលស្គាល់ក្នុងគ្រាហិរញ្ញវត្ថុ ដែលរួមបញ្ចូលក្នុង ចំណូលកិច្ចសន្យាដើមគ្រា | (១៤.៦៤៥.៨៧៣) | (៥៩.៦៨១.៩៣២) | (៥.១០៣.០៦៣) | (២០.៥០៤.១០៧) |
| បូក: | | | | |
| ការបង់មុនដែលបានទទួល | ១៤.៥៩៤.៤៥០ | ៥៩.០៣៤.៥៥១ | ១៤.៦៤៥.៨៧៣ | ៥៩.៦៨១.៩៣២ |
| | ១៤.៥៩៤.៤៥០ | ៥៩.០៣៤.៥៥១ | ១៤.៦៤៥.៨៧៣ | ៥៩.៦៨១.៩៣២ |

## ២០. សំវិធានធន

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ការធានា** | | | | |
| នាថ្ងៃទី១ ខែមករា | ២.៣២១.៥៦០ | ៩.៤៦០.៣៥៧ | ១.៣៦១.៧០៤ | ៥.៤៧១.៣២៧ |
| (ត្រលប់) ឬបានទទួលស្គាល់ក្នុង ចំណេញ ឬខាត | (៦.១១៤) | (៩៤.៣៧៨) | ៩៥៩.៨៥៦ | ៣.៩៨៩.០៣០ |
| នាថ្ងៃទី៣១ ខែធ្នូ | ២.៣១៥.៤៤៦ | ៩.៣៦៥.៩៧៩ | ២.៣២១.៥៦០ | ៩.៤៦០.៣៥៧ |

សំវិធានធនសម្រាប់ការទាមទារលើការធានា តំណាងដោយតម្លៃបច្ចុប្បន្ននៃការប៉ាន់ស្មានដ៏ល្អបំផុតរបស់នាយកនៃកាតព្វកិច្ចសេដ្ឋកិច្ចនាពេលអនាគតដែលគប្បីឱ្យក្រុមហ៊ុនមានកាតព្វកិច្ច ត្រូវធានាលើទំនិញ និងសេវាកម្មដែលបានលក់។ សំវិធានធនត្រូវបានទទួលស្គាល់ដោយពឹងផ្អែកលើការប៉ាន់ស្មាន ដែលធ្វើឡើងពីទិន្នន័យធានាប្រវត្តិសាស្ត្រដែលទាក់ទងនឹងផលិតផលស្រដៀងគ្នា។

## ២១. ឥណទាន និងប្រាក់កម្ចី

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ពាន់រៀល | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល |
|---|---|---|---|---|---|
| **រយៈពេលខ្លី** | | | | | |
| ឥណទានធនាគារ | (ក) | ៤.៦១៤.០៨៣ | ១៨.៦៦៣.៨០៤ | ៤៤.៧៦៣.២៦៦ | ១៨២.៤១០.៣០៥ |
| ប័ណ្ណបំណុលសាជីវកម្ម | (ខ) | ២.៧៤០.០៤៤ | ១១.០៨៣.៦៤០ | - | - |
| | | ៧.៣៥៤.១២៧ | ២៩.៧៤៧.៤៤៤ | ៤៤.៧៦៣.២៦៦ | ១៨២.៤១០.៣០៥ |
| **រយៈពេលវែង** | | | | | |
| ប័ណ្ណបំណុលសាជីវកម្ម | (ខ) | ១៦.០៣៩.៣១២ | ៦៤.៨៧៩.០១៧ | - | - |
| | | ១៦.០៣៩.៣១២ | ៦៤.៨៧៩.០១៧ | - | - |
| | | ២៣.៣៩៣.៤៣៩ | ៩៤.៦២៦.៤៦១ | ៤៤.៧៦៣.២៦៦ | ១៨២.៤១០.៣០៥ |

**អ អិម អេ ( ខេមបូឌា ) ម.ក**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ២១. ឥណទាន និងប្រាក់កម្ចី ( ត )

